ISSN 1560-7615


# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៥ លេខ៣ | កក្កដា - កញ្ញា ឆ្នាំ២០០១ | តម្លៃ: ១.៥០០រ


# ឧស្សាហកម្មកាត់ដេរនៅប្រទេសកម្ពុជា

**ឧស្សាហកម្មកាត់ដេរនៅប្រទេសកម្ពុជា បានរីកលូតលាស់យ៉ាងខ្លាំងក្លាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ នៅក្នុងអត្ថបទនេះ អ្នកស្រាវជ្រាវ ជា ហួត និង សេដ្ឋវិទូជាន់ខ្ពស់ សុក ហាច បានបូកសរុបលទ្ធផលនៃការសិក្សាមួយដែល វបសអ បានធ្វើនៅក្នុងឆ្នាំ២០០០ និង ២០០១ ស្ដីពីដំណើរការនៃឧស្សាហកម្មនេះ *។**



*នៅក្នុងឆ្នាំ២០០០ ការនាំចេញសំលៀកបំពាក់របស់ប្រទេសកម្ពុជា មានតំលៃសរុបជិត ៩៨៥លានដុល្លារ ឬ ៧០% នៃការនាំចេញទាំងអស់ ហើយវិស័យនេះបានផ្ដល់ការងារអោយពលរដ្ឋយើងជាង ១៦០.០០០នាក់ ។*

ក្នុងមួយរយៈពេលខ្លីប៉ុណ្ណោះ ឧស្សាហកម្មកាត់ដេរកម្ពុជា បានរីកលូតលាស់ពីកំរិតសឹងតែគ្មានអ្វីសោះ មកក្លាយជាវិស័យនាំចេញដែលនាំមុខគេនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងឆ្នាំ ២០០០ ការនាំចេញសំលៀកបំពាក់របស់ប្រទេសកម្ពុជា មានតំលៃសរុប ៩៨៥លាន ដុល្លារ ឬ ៧០% នៃការនាំចេញទាំងអស់ ហើយ វិស័យនេះបានផ្ដល់ការងារអោយពលករយើង ជាង ១៦០.០០០នាក់ ។

សំរាប់រយៈពេលខ្លី ឧស្សាហកម្មនេះហាក់ដូចជាមានអនាគតល្អ ពីព្រោះពលកម្មនៅកម្ពុជា មានតំលៃទាបជាងប្រទេសផលិតសំលៀកបំពាក់ផ្សេងទៀតដូចជា ស៊ីរលង្កា, ថៃ, និងហ្វីលីពីនជាដើម, ហើយការលើកទឹកចិត្តដែលរដ្ឋាភិបាលកម្ពុជាផ្ដល់ឱ្យអ្នកវិនិយោគ បរទេសក៏មានលក្ខណៈទាក់ទាញខ្លាំងដែរ ។ ក្នុងការធ្វើពាណិជ្ជកម្មជាមួយទីផ្សារអន្តរជាតិធំៗ ដែលផ្ដល់ប្រាក់ចំណេញ ច្រើនដូចជា សហរដ្ឋអាមេរិក (US) និង សហភាពអឺរ៉ុប (EU) ជាដើម ប្រទេសកម្ពុជាក៏បានទទួលលក្ខខណ្ឌអំណោយផលខ្លាំងជាងប្រទេសផ្សេងទៀតដែលមានពលកម្មថោកដូចជា ចិន និង វៀតណាមនោះដែរ ។

ពិតមែនហើយ កត្តាទាំងឡាយខាងលើបានបង្ហាញនូវនិទស្សន៍ដ៏ល្អសំរាប់ឧស្សាហកម្មកាត់ដេរកម្ពុជាក្នុងរយៈពេលខ្លី ក៏ប៉ុន្តែសំរាប់រយៈពេលវែងវិញ វាយ៉ាងដូចម្ដេចដែរ? តើឧស្សាហកម្មកាត់ដេរកម្ពុជាមានចីរភាពប៉ុណ្ណានៅពេលដែលចិន និងវៀតណាម បានទទួលលក្ខខណ្ឌធ្វើពាណិជ្ជកម្មល្អដូចគ្នាជាមួយ US និង EU? តើប្រទេសកម្ពុជា ត្រូវអនុវត្តវិធានការអ្វីខ្លះ ដើម្បីត្រៀមខ្លួនចំពោះការប្រកួតប្រជែងដ៏ខ្លាំងក្លាក្នុងពេលអានាគតដ៏ខ្លីខាងមុខ? មួយចំណែកទៀត តើរដ្ឋាភិបាលអាចធ្វើដូចម្ដេចបាន ដើម្បីប្រមូលចំណូលឱ្យបានច្រើនថែមទៀតពីឧស្សាហកម្មកាត់ដេរ ដោយជៀសវាងការប៉ះពាល់មិនល្អដល់អ្នកវិនិយោគ?

ដើម្បីឆ្លើយនឹងសំនួរនានាខាងលើ និងបង្កើនការយល់ដឹងពីឧស្សាហកម្មកាត់ដេរ ក្នុងឆ្នាំ២០០០ និង ២០០១ វបសអ បានធ្វើការសិក្សាឯកសារផ្សេងៗ និងសំភាសន៍ស៊ីជំរៅជាមួយម្ចាស់រោងចក្រកាត់ដេរ មន្ត្រីរដ្ឋាភិបាល

* អត្ថបទនេះផ្អែកលើជំពូកមួយនៃរបាយការណ៍ប្រចាំឆ្នាំ ស្ដីពីសេដ្ឋកិច្ចកម្ពុជា ដែល វបសអ នឹងចេញផ្សាយក្នុងពេលដ៏ខ្លីខាងមុខ ។ មតិ និងហេតុការណ៍ទាំងឡាយ ដែលបានលើកឡើងនៅក្នុងអត្ថបទនេះ គឺជារបស់អ្នកនិពន្ធផ្ទាល់ មិនមែនជារបស់ វបសអ ទេ ។

## មាតិកា


ឧស្សាហកម្មកាត់ដេរនៅប្រទេសកម្ពុជា............................... ១
អ្នកភូមិជនជាតិដើមទំពួនសំរបខ្លួនទៅតាមការប្រែប្រួលសេដ្ឋកិច្ច.................. ៦
សម្រែកអាជីវករ ........................................................១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .................................១៤
— ស្ថានភាពក្នុងប្រទេស.................................១៧
— សន្ទស្សន៍សេដ្ឋកិច្ច .................................. ២០
សន្ទានុក្រម ................................................................ ២៣
ពត៌មានថ្មីៗពី វបសអ ........................................................២៤

កម្មករកាត់ដេរ និងថ្នាក់ដឹកនាំសហជីព ។ អត្ថបទនេះនឹងបង្ហាញលទ្ធផល និងអនុសាសន៍ខាងគោលនយោបាយមួយចំនួនដែលផុសចេញពីការសិក្សា ។

## ការរីកលូតលាស់នៃឧស្សាហកម្មកាត់ដេរ

ឧស្សាហកម្មកាត់ដេរដែលបំរើការនាំចេញ ទើបតែកើតថ្មីទេ នៅក្នុងប្រទេសកម្ពុជា ។ បើពិនិត្យនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាតែងតែផ្ដោតទៅលើផលិតកម្មកសិកម្ម ។ នៅក្រោមការគ្រប់គ្រងរបស់បារាំង (ពីឆ្នាំ១៨៦៣ ដល់ ១៩៥៣) ប្រទេសកម្ពុជា ជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើម និងជាអ្នកទិញផលិតផលសំរេច ។ ដោយឡែក សូត្រ និងកប្បាស ត្រូវបានផលិត និងកែច្នៃជាសំលៀកបំពាក់ជាលក្ខណៈអាជីវកម្មទ្រង់ទ្រាយតូច ហើយទើបតែនៅក្រោយការដណ្ដើមឯករាជ្យបានពីបារាំងក្នុងឆ្នាំ១៩៥៤ ទេ ដែលផលិតកម្មវាយនភណ្ឌជាលក្ខណៈឧស្សាហកម្មបានចាប់ផ្ដើមឡើងនៅក្នុងប្រទេសកម្ពុជា ។

នៅចុងទសវត្សរ៍១៩៥០ ក្រុមហ៊ុន SONATEX (ក្រុមហ៊ុនវាយនភណ្ឌរបស់រដ្ឋ) ត្រូវបានបង្កើតឡើង ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំជាបន្តមកទៀត រោងចក្រវាយនភណ្ឌ និងសំលៀកបំពាក់មួយចំនួន ត្រូវបានកសាងឡើងនៅកំពង់ចាម បាត់ដំបង និងភ្នំពេញ ។ ប្រជាជនកម្ពុជាច្រើនពាន់គ្រួសារ បានទទួលអត្ថប្រយោជន៍ពីការងារនៅក្នុងរោងចក្រទាំងនេះ ប៉ុន្តែគួរឱ្យស្ដាយដែលរោងចក្រត្រូវខូចខាតអស់ ដោយសារតែការប្រយុទ្ធគ្នានៅក្នុងទសវត្សរ៍ ១៩៧០ ។ នៅក្នុងទស្សវត្សរ៍១៩៨០ រោងចក្រមួយចំនួនត្រូវបានជួសជុលឡើងវិញដោយប្រើជំនួយអន្តរជាតិ ប៉ុន្តែក្រណាត់សាច់អំបោះ និងគ្រឿងផ្គត់ផ្គង់ខាងពេទ្យផ្សេងៗ ដែលជាផលិតផលនៃរោងចក្រទាំងនេះ សំរាប់តែបំរើ ការប្រើប្រាស់ក្នុងស្រុកប៉ុណ្ណោះ ។

នៅដើមទសវត្សរ៍១៩៩០ នៅពេលប្រទេសកម្ពុជា បានទទួលសុខសន្តិភាពជាលើកដំបូងក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក និងនៅពេលដែលរដ្ឋាភិបាលបានកែប្រែសេដ្ឋកិច្ចពីប្រព័ន្ធតាមផែនការប្រមូលផ្ដុំ មកជាប្រព័ន្ធទីផ្សារវិញ ឧស្សាហកម្មសំលៀកបំពាក់សំរាប់ការនាំចេញក៏ចាប់ផ្ដើមលូតលាស់ឡើង ។ វាបានរីកដុះដាលយ៉ាងឆាប់រហ័សនៅក្រោយឆ្នាំ១៩៩៦ នៅពេលមានការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្ម មានលក្ខខណ្ឌអំណោយផលល្អ គឺដំបូងធ្វើកិច្ចព្រមព្រៀងជាមួយ EU និងបន្ទាប់មកទៀតជាមួយ US ។

ពីដំបូង EU គឺជាទិសដៅធំជាងគេសំរាប់សំលៀកបំពាក់នាំចេញ ប៉ុន្តែនៅពេលមានទំនាក់ទំនងពាណិជ្ជកម្មអំណោយផលជាមួយ US ការនាំចេញទៅ US ក៏បានកើនលើសការនាំចេញទៅ EU ទៀត ។ ក្នុងឆ្នាំ១៩៩៩ ដោយសារសំលៀកបំពាក់នាំចេញទៅ US មានចំនួនច្រើន រដ្ឋាភិបាលអាមេរិកបានដាក់កូតាលើ អីវ៉ាន់ ១២មុខ ដែលមានៈ ស្រោមដៃ អាវក្រៅ ខោវែង អាវសឺមី អាវស្រី អាវយឺត និងខោអាវក្នុង ។ រដ្ឋាភិបាលអាមេរិកបានសន្យាតំឡើង កូតាឱ្យកម្ពុជា ៦% ក្នុងមួយឆ្នាំ និងតំឡើងខ្ពស់ជាងនេះទៀត បើសិនកម្ពុជា កែលំអថែមនូវស្តង់ដារពលកម្ម។

## ឧស្សាហកម្មកាត់ដេរក្នុងពេលសព្វថ្ងៃ

អ្នកស្រាវជ្រាវរបស់ វិបសអ បានរកឃើញថា ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ប្រើពលកម្មច្រើនណាស់ ហើយកន្លងមកមានដំណើរការល្អ ពីព្រោះប្រទេសកម្ពុជាមានកំលាំងពលកម្មច្រើនដែលមានតំលៃថោក ។ ក្នុងពេលបច្ចុប្បន្ន ឧស្សាហកម្មនេះមានកំរិតអភិវឌ្ឍន៍ស្មើគ្នានឹងប្រទេសហ្វីលីពីន ថៃ ម៉ាឡេស៊ី និងសិង្ហបូរី ក្នុងទសវត្សរ៍១៩៧០ ដែលនៅពេលនោះឧស្សាហកម្មទើបចាប់ផ្ដើម ឯតំលៃពលកម្មក៏នៅថោក ។ ដូចបទពិសោធន៍ក្នុងប្រទេសទាំងនេះដែរ រដ្ឋាភិបាលកម្ពុជាសង្ឃឹមថា ឧស្សាហកម្មកាត់ដេរនឹងបង្កើតជាគ្រឹះសំរាប់ឧស្សាហកម្មឯទៀតៗ ដូចជា ផលិតកម្មគ្រឿងអេឡិចត្រូនិកជាដើម ។

ការស្រាវជ្រាវបានបង្ហាញថា ឧស្សាហកម្មកាត់ដេរប្រមូលផ្ដុំជាសំខាន់នៅក្នុងក្រុងភ្នំពេញ និងបណ្ដាខេត្តជិតខាង ។ កម្មករកាត់ដេរកម្ពុជាភាគច្រើនគឺជាស្ត្រីវ័យក្មេង មានការអប់រំតិចតួច និងគ្មានជំនាញ ដែលបានធ្វើចំណាកស្រុកមកពីតំបន់ជនបទ ។ ម្ចាស់រោងចក្រគឺជាអ្នកវិនិយោគមកពីហុងកុង, តៃវ៉ាន់ ចិន សិង្ហបូរី កូរ៉េខាងត្បូង និង US ។ អ្នកវិនិយោគក្នុងស្រុកមានតិចតួចទេ ហើយភាគច្រើននៃអ្នកគ្រប់គ្រងរោងចក្រក៏ជាជនបរទេសដែរ ។

តាមស្ថិតិរបស់ក្រសួងពាណិជ្ជកម្ម តំលៃសរុបនៃសំលៀកបំពាក់នាំចេញរបស់កម្ពុជាកើនពី ៥៣៣លានដុល្លារ ក្នុងឆ្នាំ១៩៩៩ ដល់ ៩៨៥លានដុល្លារក្នុងឆ្នាំ២000 (កំណើន ៥0%) ។ នៅឆ្នាំ២000 សំលៀកបំពាក់នាំចេញតំណាងឱ្យ ៧0% នៃទំនិញ និងសេវានាំចេញសរុបរបស់កម្ពុជា (ឬ ៨៦% នៃទំនិញនាំចេញ) ។ ពីឆ្នាំ១៩៩៩ ដល់ ២000 ប្រទេសទិញសំលៀកបំពាក់ពីកម្ពុជា បានកើនចំនួនពី ២៤ប្រទេស ដល់ ៣៨ប្រទេស ។ ប៉ុន្តែទីផ្សារ US និង EU នៅតែស្រូបយកអស់ ៩៧% នៃការនាំចេញរបស់កម្ពុជាជាបន្តទៀត (ក្រាហ្វិក១) ។

ដូចបានលើកឡើងហើយ តាំងពីឆ្នាំ១៩៩៨ មក US បានក្លាយជាទីផ្សារធំជាងគេសំរាប់សំលៀកបំពាក់កម្ពុជា ។ ទោះបីមានការដាក់កូតាលើសំលៀកបំពាក់ប្រភេទខ្លះក៏ដោយ ក៏សំលៀកបំពាក់នាំចេញទៅ US បានកើន ៤៦% ក្នុងឆ្នាំ១៩៩៩ និង ៧៨% ក្នុងឆ្នាំ២000 ពីព្រោះកម្ពុជាបានពង្រីកផលិតកម្មសំលៀកបំពាក់ក្នុងប្រភេទមិនជាប់កូតា ។ ក្នុងឆ្នាំ១៩៩៩ ទីផ្សារ US ស្រូបយកប្រហែល ៨៨% នៃសំលៀកបំពាក់នាំចេញរបស់កម្ពុជា ប៉ុន្តែក្នុងឆ្នាំ២000 វាបានធ្លាក់ចុះមកត្រឹម ៧៦% វិញ ។ ប៉ុន្តែគិតជាសរុប សំលៀកបំពាក់នាំចេញបានបន្តកើនឡើង ពីព្រោះការនាំចេញទៅអឺរ៉ុបបានកើនយ៉ាងគំហុកពី ៥៨លានដុល្លារក្នុងឆ្នាំ១៩៩៩ ដល់ទៅ ២២១លានដុល្លារក្នុងឆ្នាំ២000 ។

**ក្រាហ្វិក ១. ចំនួនរោងចក្រកាត់ដេរ និងទិសដៅផលិតផល**




*ប្រភពៈ ក្រសួងពាណិជ្ជកម្ម និងព្យាករណ៍របស់ វិបសអ ។*

សំរាប់រយៈពេលខ្លីកូតា US ហាក់ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរណាស់ណាទេលើការនាំចេញសរុប ។ ដូចបានបញ្ជាក់ហើយ ផលិតករបាននាំចេញសំលៀកបំពាក់ក្នុងប្រភេទដែលមិនស្ថិតនៅក្រោមកូតា US ហើយការនាំចេញទៅអឺរ៉ុបក៏បានកើនឡើងសំបើមណាស់ដែរ ។ មួយចំណែកទៀត ដោយសារមានការកែលំអលក្ខខណ្ឌការងារនៅក្នុងប្រទេសកម្ពុជា រដ្ឋាភិបាល US បានយល់ព្រមតំឡើងបរិមាណទំនិញនាំចូលដែលជាប់កូតា និងសន្យាតំឡើងឱ្យថែមទៀត បើសិនស្តង់ដាពលកម្មបន្តកែលំអឡើង ។

ពួកម្ចាស់រោងចក្រដែលក្រុមអ្នកស្រាវជ្រាវ វបសអ សំភាសន៏បានបញ្ជាក់ថា បើសិនជាកម្ពុជា អាចពង្រីកការលក់ចេញនៅក្នុងតំបន់ និងទៅឱ្យប្រទេសអភិវឌ្ឍន៏ផ្សេងៗទៀត ហើយបរិយាកាសនយោបាយ និងសង្គមកិច្ចក្នុងប្រទេសកម្ពុជានៅតែអំណោយផល ឧស្សាហកម្មកាត់ដេរ នឹងនៅតែបន្តរីកដុះដាលទៅមុខទៀត (យ៉ាងហោចណាស់ក៏ក្នុងរយៈពេលខ្លីដែរ) ។

## កំលាំងពលកម្មក្នុងឧស្សាហកម្មកាត់ដេរ

ដូចបានលើករួចមកហើយ នៅកម្ពុជា ឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌ មានតួនាទីយ៉ាងសំខាន់ក្នុងការប្រើប្រាស់ពលកម្មមានជំនាញទាប ។ តាមអង្កេតមួយរបស់វិជ្ជាស្ថានជាតិស្ថិតិ ប្រហែល ៦៤% នៃពលករនៅក្នុងវិស័យកម្មន្តសាល បំរើការក្នុងឧស្សាហកម្មកាត់ដេរ ។ ប៉ុន្តែ កម្ពុជានៅតែជាប្រទេសកសិកម្មជាសំខាន់នៅឡើយ ដូច្នេះកំលាំងពលកម្មសរុបដែលបំរើការក្នុងឧស្សាហកម្មកាត់ដេរ មានទំហំប្រៀបធៀបតូចនៅឡើយ (ប្រហែល ៤% នៃកំលាំងពលកម្មសរុប) ។ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ១៩៩៩ ឧស្សាហកម្មកាត់ដេរទំនើបបង្កើតបានជិតដល់ ៤០.០០០ការងារថ្មីក្នុងមួយឆ្នាំៗ ។ ប៉ុន្តែដោយ សារវិនិយោគបានធ្លាក់ចុះ ការងារបង្កើតថ្មី មានប្រហែលតែ ២០.០០០ ប៉ុណ្ណោះក្នុងឆ្នាំ២០០០ ។

ដូចក្នុងប្រទេសផ្សេងទៀតដែរ មួយចំណែកធំនៃកំលាំងពលកម្មក្នុងផលិតកម្មសំលៀកបំពាក់ និងស្បែកជើង នៅកម្ពុជា គឺជាស្ត្រីភេទ (ប្រហែល ៨៥%) ។ តាមប្រភពពត៌មានពីសមាគមអ្នកផលិតសំលៀកបំពាក់កម្ពុជា (Garment Manufacturers Association of Cambodia: GMAC) និងតាមលទ្ធផលនៃអង្កេតនានាដែលអ្នកស្រាវជ្រាវ វបសអ បានធ្វើក្នុងឆ្នាំ២០០០ គេបានដឹងថា ប្រហែល ៩០% នៃពលករគឺជាប្រជាជនដែលចេញមកពីតំបន់ជនបទនានានៅជិតក្រុងភ្នំពេញ ។

ប្រហែល ៥០% នៃកម្មករកាត់ដេរដែលអ្នកស្រាវជ្រាវ វបសអ សំភាសន៏បានរាយការណ៏ថា ពួកខ្លួនត្រូវបង់ជាមធ្យម ៣៨ដុល្លារ (ប្រហែលបៀវត្សរ៍មួយខែ) ដើម្បីបានការងារធ្វើ ។ "ប្រាក់កំរៃ" នេះ ត្រូវបង់ទៅឱ្យមនុស្សច្រើនប្រភេទ –ឆ្មាំសន្តិសុខរោងចក្រ, អ្នកបកប្រែ, គួកជេរកការងារឱ្យធ្វើ (Maclean 1999) ។ ដើម្បីបង់ប្រាក់កំរៃនេះ ពលករ ៥៧% ត្រូវខ្ចីប្រាក់គេ ។ តាមពតិមានពី GMAC ពួកម្ចាស់រោងចក្រប្រឆាំងយ៉ាងខ្លាំងក្លាចំពោះរបៀបរបបទារយក "ប្រាក់កំរៃ" ក្នុងការផ្តល់ការងារឱ្យធ្វើ ហើយម្ចាស់រោងចក្របានសំណូមពរឱ្យកម្មករប្តឹងតវ៉ា បើមានរឿងបែបនេះកើតឡើង ។ ប៉ុន្តែក្នុងចំនោមកម្មករអ្នកឆ្លើយសំភាសន៏ គ្មានមួយណាប្រុងធ្វើការតវ៉ាទេ ។

តាមអង្កេតរបស់ វបសអ ស្ត្រីក្មេងៗជាកម្មកររោងចក្រកាត់ដេរ មានការអប់រំជាមធ្យមកំរិតទាប ក្នុងនេះ ៦១% បានរៀនត្រឹមបឋមសិក្សា, ៣១% រៀនដល់មធ្យមសិក្សា, ហើយមានតែ ៨% ប៉ុណ្ណោះដែលមានសញ្ញាប័ត្រកំរិតមធ្យមសិក្សា ។

## បន្ទុកចំណាយទូទៅ

ពួកម្ចាស់រោងចក្រដែលអ្នកស្រាវជ្រាវ វបសអ សំភាសន៏ក្នុងពេលស្រាវជ្រាវបានប្រាប់ថា តំលៃសាងសង់រោងចក្រកាត់ដេរមួយចំណុះកម្មករ ៥០០នាក់ (មិនគិតថ្លៃដីទេ) គឺប្រហែល ៧០០.០០០ដុល្លារ ។ ផ្អែកលើតំលៃឯកតានេះ ទ្រព្យសកម្មជាប់លាប់នៃរោងចក្រកាត់ដេរទាំង ២២០រោងចក្រដែលកំពុងដំណើរការក្នុងប្រទេសកម្ពុជា អាចប៉ាន់បានថា មានតំលៃប្រហែល ២០០លានដុល្លារ ។ បើបូកចូលទាំងទុនបង្វិលដែលត្រូវប្រើប្រាស់នៅក្នុងដំណើរការរោងចក្រផង ទុនសរុបដែលបានវិនិយោគក្នុងឧស្សាហកម្ម កាត់ដេរពីឆ្នាំ១៩៩៣ ដល់ ២០០០ មានប្រហែល ៥០០លានដុល្លារ ។

ម្ចាស់រោងចក្របានប៉ាន់ស្មានថា "ចំនាយការិយាល័យនិយម" ក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានទំហំ ប្រហែល ៧% នៃប្រាក់លក់បាន គឺប្រមាណ ៧០លានដុល្លារក្នុងឆ្នាំ២០០០ ។ "ចំណាយការិយាល័យនិយម" ដែលមានជាអាទិ ច្បាប់អនុញ្ញាតឱ្យសាងសង់និងដំណើរការរោងចក្រ, ការនាំចូលវត្ថុធាតុដើម និងការនាំចេញសំលៀកបំពាក់, បូកនឹងបន្ទុកចំណាយដែលទាក់ទិននឹងការយឺតយ៉ាវដើម្បីបានច្បាប់ទាំងនេះ, ត្រូវបានប៉ាន់ស្មានទៀតថា មានទំហំស្មើគ្នានឹងប្រាក់ចំណេញសុទ្ធ ឬស្មើនឹងពាក់កណ្តាលនៃចំណាយពលកម្មសរុប ។ បើសិនគេយកប្រាក់នេះទៅផ្តល់ឱ្យបុគ្គលិកវិញ ប្រាក់បៀវត្សរ៍ជាមធ្យមរបស់កម្មកររោងចក្រត្រូវបានលើសពី ១០០ដុល្លារក្នុងមួយខែ ។ បើសិនគេយកវាទៅវិនិយោគបន្តក្នុងវិស័យកាត់ដេរ គេអាចសង់បានជាង ៧០រោងចក្រថ្មីក្នុងមួយឆ្នាំៗ ។ បើសិនយកប្រាក់នេះទៅអភិវឌ្ឍប្រព័ន្ធស្រោចស្រពនៅតាមជនបទ គេអាចពង្រីកដីមានប្រព័ន្ធស្រោចស្រព បានប្រហែល ១៤០.០០០ហិកតារថែមទៀតក្នុងមួយឆ្នាំៗ ។

ដើម្បីប៉ះប៉ូវ "ចំណាយការិយាល័យនិយម" ដ៏ខ្ពស់នេះ រដ្ឋាភិបាលកម្ពុជាបានផ្តល់ការលើកលែងពន្ធជាច្រើនដល់ឧស្សាហកម្មកាត់ដេរ ។ សំរាប់ផលិត

**ក្រាហ្វិក ២. ចំណាយលើផលិតកម្មនៅក្នុងឧស្សាហកម្មកាត់ដេរ**




*ប្រភព: សំភាសន៏របស់ វបសអ ជាមួយពួកម្ចាស់រោងចក្រ ឆ្នាំ២០០០*

កម្មសំលៀកបំពាក់ បច្ចុប្បន្នពុំមានយកពន្ធគយលើវត្ថុធាតុដើមនាំចូលពុំមានយកពន្ធលើប្រាក់ចំណេញ (លើកលែងតាមច្បាប់វិនិយោគ) និងពុំមានយកអាករលើតំលៃបន្ថែមទេ ។ នៅក្នុងសុន្ទរកថានាឱកាស "វេទិកាជួបគ្នារវាងរដ្ឋាភិបាល និងវិស័យឯកជន" លើកទី៣ កាលពីខែកុម្ភៈ ឆ្នាំ២០០១, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ថា រដ្ឋាភិបាលបានផ្តល់ការលើកលែងពន្ធ ១៦៣លានដុល្លារ ដល់ឧស្សាហកម្មកាត់ដេរក្នុងឆ្នាំ២០០០ ។ ការលើកលែងពន្ធទាំងនេះ គឺជាការលើកទឹកចិត្តដ៏ចំបងចំពោះវិនិយោគិនបរទេសក្នុងវិស័យកាត់ដេរ ប៉ុន្តែពួកជំនាញការខាងឧស្សាហកម្មបានបញ្ជាក់ថា វាអាចប៉ះប៉ូវបានតែមួយចំណែកនៃ "ចំណាយការិយាល័យនិយម" ដ៏ខ្ពស់នេះតែប៉ុណ្ណោះ ។

ពួកម្ចាស់រោងចក្របានរាយការណ៍ថា ក្នុងតំលៃ ១០០ដុល្លារនៃសំលៀកបំពាក់នាំចេញ មាន ៦៣ដុល្លារជាចំនាយលើវត្ថុធាតុដើមនាំចូល, និង ៤ដុល្លារជាចំនាយលើការផ្គត់ផ្គង់សាធារណៈ (ទឹក ភ្លើង...) និងចំណាយតូចតាចផ្សេងៗ ។ ដូច្នេះនៅក្នុង ១០០ដុល្លារនៃតំលៃសំលៀកបំពាក់លក់ចេញ គឺមានប្រហែលមួយភាគបីជាតំលៃបន្ថែម ។ ចំណាយពលកម្មនៅក្នុងឧស្សាហកម្មកាត់ដេរ តំណាងឱ្យប្រហែល ១៣% នៃថ្លៃលក់បានសរុប ឯ "ចំណាយការិយាល័យនិយម" តំណាងឱ្យប្រហែល ៧% ។ ប្រាក់ចំណេញដុល (គិតទាំងរំលស់មូលធនផង) ត្រូវបានប៉ាន់ស្មាននៅក្នុងអង្កេត វបសអ ថា មានទំហំប្រហែល ១៣% (ក្រាហ្វិក២) ។ ទោះបីប្រាក់ចំណូលពីការលក់សំលៀកបំពាក់នាំចេញមានកំរិតខ្ពស់ខ្លាំងក៏ដោយ ក៏ពួកម្ចាស់រោងចក្របានប៉ាន់ថា មានប្រហែលតែ ២៥% នៃប្រាក់ចំណូលពីការលក់ប៉ុណ្ណោះ ដែលត្រូវបានរក្សាទុកនៅក្នុងប្រទេសកម្ពុជា ។

## សមាគមអ្នកផលិតសំលៀកបំពាក់នៅកម្ពុជា

សមាគមអ្នកផលិតសំលៀកបំពាក់នៅកម្ពុជា (Garment Manufacturers Association of Cambodia: GMAC) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦ គឺជាអ្នកមានតួនាទីសំខាន់បំផុត នៅក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មកាត់ដេរនៅកម្ពុជា ។ ក្នុងឆ្នាំ១៩៩៧ សមាគមដ៏ខ្លាំងនេះ បានលើកទឹកចិត្តយ៉ាងសកម្មឱ្យរដ្ឋាភិបាលស្វែងរកលក្ខខណ្ឌធ្វើពាណិជ្ជកម្មដែលមានលក្ខណៈអនុគ្រោះយ៉ាងពិសេស ដូចជា ប្រព័ន្ធអនុគ្រោះទូទៅ (GSP) និងសិទ្ធិក្នុងការទទួលលក្ខខណ្ឌអនុគ្រោះខ្ពស់បំផុត (MFN) ជាដើម ពីបណ្តាប្រទេសអភិវឌ្ឍន៍ នានា (ជាពិសេស US និង EU) ។ សមាគមក៏បានជួយមតិដល់រដ្ឋាភិបាល ពីវិធីជំរុញឧស្សាហកម្មកាត់ដេរនៅកម្ពុជា និងបានដើរតួជាអ្នកសំរុះសំរួលនៅក្នុងទំនាស់រវាងម្ចាស់រោងចក្រកាត់ដេរ និងកម្មករ ។

## សហជីពកម្មករកាត់ដេរ

តាមរបាយការណ៍មួយរបស់ស្ថានទូត សហរដ្ឋអាមេរិកដែលបានផ្សព្វផ្សាយក្នុង ឆ្នាំ២០០០ ការចូលសហជីពនៃកំលាំង ពលកម្មកម្ពុជាមិនសូវខ្លាំងក្លាទេនៅខាង ក្រៅវិស័យកម្មន្តសាល ។ មកដល់ខែមិថុនា ឆ្នាំ២០០០ ក្នុងប្រទេសកម្ពុជា មានសហ ជីពពលករសរុប ១០៦សហជីពដែលបាន ចុះបញ្ជីហើយ ក្នុងនេះភាគច្រើន តំណាងឱ្យកម្មករកាត់ដេរ ។ សហជីពកាត់ដេរទាំង អស់ជាសមាជិកនៃសហព័ន្ធណាមួយក្នុងចំណោមសហព័ន្ធពលករជាតិទាំងប្រាំ ។ នៅ កម្ពុជា ការចរចាជារួមឃើញមានតិចតួច បំផុត ប៉ុន្តែសហជីពមួយចំនួន មានមតិថាវាកំពុងកើតមានឡើងហើយ ។ អ្វីដែលគេហៅថា "ការចរចា ជារួម" គឺជាការចរចាដើម្បីឱ្យនិយោជកគោរពតាមច្បាប់ការងារ ។ ការចរចាជារួមដែលសហជីពធ្វើជាមួយនិយោជក ដើម្បីទាមទារលក្ខខណ្ឌល្អជាងអ្វីដែលច្បាប់បានតំរូវមិនទាន់ឃើញមាននៅឡើយទេ ។ មួយចំនែកទៀត សហជីពក៏មិនទាន់កសាងភាពជាដៃគូដែលមានផ្លែផ្កាល្អជាមួយថ្នាក់គ្រប់គ្រងរោងចក្រ និងរដ្ឋាភិបាលបាននៅឡើយ (US Embassy 2000) ។

## ប្រាក់កំរៃ, លក្ខខណ្ឌការងារ និងការតវ៉ា

ទិន្នន័យស្ថានទូតអាមេរិក បានបង្ហាញថា នៅកម្ពុជា មានកូដកម្ម ៧៦ លើកក្នុងឆ្នាំ១៩៩៩ និង ៣៥លើកក្នុងរយៈពេល ៧ខែដើមឆ្នាំ២០០០ (US Embassy 2000) ។ ជាទូទៅកូដកម្មជាប់ទាក់ទិននឹងម៉ោងធ្វើការ, ប្រាក់កំរៃ, និងម៉ោងធ្វើការបន្ថែមច្រើនហួសពេក ។ ក្នុងខែមិថុនា ២០០០ កូដកម្មមួយ ដែលដឹកនាំដោយសហជីពពលករសេរីនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC) ព្រមទាំងសម្ព័ន្ធនៃបណ្តាសហជីពរោងចក្រកាត់ដេរ បានទាមទារឱ្យមានការកែលំអលក្ខខណ្ឌធ្វើការងារ និងការតំឡើងប្រាក់បៀវត្សរ៍អប្បបរមា គឺកាត់បន្ថយម៉ោងធ្វើការពី ៤៨ម៉ោង មក ៤៤ម៉ោង ក្នុងមួយអាទិត្យ និងតំឡើង បៀវត្សរ៍អប្បបរមាពី ៤០ដុល្លារ ដល់ ៧០ដុល្លារក្នុងមួយខែ ។

**តារាង ១. ម៉ោងធ្វើការ និងប្រាក់ខែ (គិតជាដុល្លារ) នៅក្នុងឧស្សាហកម្មកាត់ដេរ ពីបណ្តាប្រ ទេសអាស៊ានជ្រើសរើសមួយចំនួន**

| ប្រទេស (1) | ឆ្នាំ | ចំនួនម៉ោងធ្វើការក្នុងមួយអាទិត្យ | បៀវត្សរ៍ជាអប្បបរមាកំនត់ដោយច្បាប់ (2) | មធ្យមភាគប្រាក់ខែក្នុងមួយខែ | អត្រាប្រាក់ខែតាមម៉ោង(3) |
|---|---|---|---|---|---|
| ម៉ាឡេស៊ី | 1995 | 48 | None | 296 | 1.42 |
| ចិន | 1997 | 40 | [12 – 39] | 191 | 1.14 |
| ហ្វីលីពីន | 1999 | 48 | 130 | 182 | 0.88 |
| ថៃ | 1999 | 48 | [93 – 109] | 106 | 0.51 |
| ស៊ីរីលង្កា | 1998 | 45 | [29 – 37] | 63 | 0.31 |
| កម្ពុជា (4) | 2000 | 48 | 45 | 61 | 0.29 |
| វៀតណាម | 2000 | 48 | 45 | 60 | 0.29 |
| ឥណ្ឌា | 1999 | 48 | [ 6 – 54] | 57 | 0.27 |
| ឥណ្ឌូនេស៊ី | 1999 | 40 | [15 – 34] | 40 | 0.22 |
| បង់ក្លាដេស | 1996 | 48 | [12 – 76] | 40 | 0.19 |

*សំគាល់: (1) បែងចែកដោយអត្រាប្រាក់ខែតាមម៉ោង, (2) ប្រាក់ខែអប្បបរមាកំណត់ដោយការងារតាមកំរិតជំនាញ និងតាមតំបន់(3) មធ្យមភាគតំលៃការងារក្នុងមួយម៉ោង គណនាដោយ វបសអ(4) អង្កេតរបស់ វបសអ ។ ប្រភព: នាយកដ្ឋានការងារ និងការិយាល័យកិច្ចការពលកម្មអន្តរជាតិសហរដ្ឋអាមេរិក ។*

សំណើតំឡើង បៀវត្សរ៍នៅចំរូងចំរាស់នៅឡើយ ពីព្រោះពួកម្ចាស់រោងចក្រអះអាងថា អាជីវកម្មរបស់ខ្លួននឹងបាត់បង់លក្ខណៈប្រកួតប្រជែង បើសិនត្រូវបង់បៀវត្សរ៍ខ្ពស់បែបនេះ ។ ក្នុងខែមិថុនា ឆ្នាំ២០០០ ក្រោយពីមានការចរចាយ៉ាងយូរជាមួយរដ្ឋាភិបាល ក៏មានការព្រមព្រៀងតំឡើងបៀវត្សរ៍អប្បបរមាដល់ ៤៥ដុល្លារក្នុងមួយខែ និងមានប្រាក់ឧបត្ថម្ភបន្ថែម ៥ដុល្លារក្នុងមួយខែសំរាប់អ្នកមានវត្តមានពេញលេញល្អ ។ ក្នុងកិច្ចព្រមព្រៀងក៏មានចែងផងដែរពីការទូទាត់ប្រាក់បាយនៅពេលបុគ្គលិកធ្វើការបន្ថែមម៉ោង ។ ប៉ុន្តែគួរឱ្យស្ដាយ កិច្ចព្រមព្រៀងនេះពិបាកដាក់បង្ខំឱ្យអនុវត្ត ដូច្នេះហើយបានជាមានការរំជើបរំជួលកំលាំងពលកម្មមួយចំនួនក្នុងឆ្នាំកន្លងទៅ ។

នៅកម្ពុជា អត្រាប្រាក់កំរៃក្នុងគ្រប់វិស័យត្រូវបានកំណត់ឡើងជាសំខាន់ដោយសារកំលាំងទីផ្សារ លើកលែងតែបៀវត្សរ៍មន្ត្រីរាជការដែលរដ្ឋាភិបាល ជាអ្នកកំណត់ ។ ការស្រាវជ្រាវរបស់ វិបសអ បានរកឃើញថា បើបូកទាំងម៉ោងបន្ថែមដ៏ច្រើនផង កម្មកររោងចក្រកាត់ដេរមានចំណូលជាមធ្យម ៦១ដុល្លារក្នុងមួយខែ ហើយប្រាក់នេះប្រហែលពាក់កណ្ដាលត្រូវចំណាយសំរាប់ការចិញ្ចឹមជីវិត (ឈ្នួលផ្ទះ, ចំណាយហូបចុក, ការធ្វើដំណើរចុះឡើងពីផ្ទះទៅរោងចក្រ) ។ ប្រាក់សន្សំដុលរបស់កម្មកររោងចក្រ មានកំរិតទាបជាងអ្នករត់ម៉ូតូឌុប និងអ្នកធាក់ស៊ីក្លូទៅទៀត ។ ដើម្បីអាចផ្ញើប្រាក់មួយចំនួនទៅផ្ទះសំរាប់ជួយដល់ក្រុមគ្រួសារនៅជនបទ កម្មករត្រូវតែកាត់បន្ថយចំណាយរបស់ខ្លួនផ្ទាល់ និងខំធ្វើការម៉ោងបន្ថែមឱ្យបានច្រើនបំផុត ។ កម្មករអ្នកឆ្លើយសំភាសន៍ជាច្រើននាក់បានលើកឡើងថា ពួកគេជាច្រើននាក់បានធ្លាក់ខ្លួនឈឺជាញឹកញាប់ ដោយសារការហូបចុកមិនគ្រប់គ្រាន់ និងធ្វើការច្រើនម៉ោងពេក ។

## ការកែលំអស្តង់ដាពលកម្ម

ទោះបីលក្ខខណ្ឌពលកម្មកម្ពុជា មិនទាន់ស្របតាមស្តង់ដាពលកម្មអន្តរជាតិពេញលេញក៏ដោយ ក៏ប្រទេសកម្ពុជាបានរីកចំរើនច្រើនហើយក្នុងវិស័យសិទ្ធិពលករ ដែលមានជាអាទិ៖

- គ្មានការរើសអើងក្នុងទីផ្សារពលកម្ម
- ការហាមឃាត់ពលកម្មចាប់បង្ខំ ឬពលកម្មដោះបំណុល
- ការហាមឃាត់អាជីវកម្មលើពលកម្មកុមារ

របាយការណ៍មួយរបស់ស្ថានទូតអាមេរិក បានបង្ហាញថា ការអនុវត្តន៏ច្បាប់ការងារនៅក្នុងប្រទេសកម្ពុជា ត្រូវបានអាជ្ញាធរពលកម្មអន្តរជាតិនានាចាត់ទុកថាអាចទទួលយកបាន ប៉ុន្តែនៅមានរោងចក្រមួយចំនួនដែលមិនទាន់ប្រតិបត្តិតាមច្បាប់ការងារនៅឡើយ ។ ឧទាហរណ៍ ទោះបីរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ការងារ បានធានាយ៉ាងច្បាស់នូវសិទ្ធិកសាងសមាគម (សហជីព) ក៏ដោយ ក៏ក្នុងការអនុវត្តន៏ជាក់ស្តែងនៅមានបញ្ហាចោទមួយចំនួននៅឡើយ ។ របាយការណ៏ក៏បានលើកដែរថា កំរិតនៃការរំខានរុកគួន (មានទាំងការបញ្ឈប់អ្នកដឹកនាំសហជីព ពីការងារ), ការគំរាមសំឡុតកម្មករ, ការលូកដៃកក្កូរកកាយក្នុងពេលបង្កើតសហជីព, និងសកម្មភាពផ្សេងៗ ប្រឆាំងនឹងសហជីព បានថយចុះជាបណ្ដើរៗ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ (US Embassy 2000) ។

## និទស្សន៍រយៈពេលវែងសំរាប់ការនាំចេញសំលៀកបំពាក់

ឧស្សាហកម្មកាត់ដេរក្នុងប្រទេសកម្ពុជា ហាក់ដូចបានរីកលូតលាស់ដោយសារសម្បទានខាងពាណិជ្ជកម្មផ្តល់ឱ្យដោយប្រទេសអភិវឌ្ឍន៏មួយចំនួន និងដោយសារពលកម្មនៅកម្ពុជាមានតំលៃថោក ។ រហូតមកដល់ពេលនេះ ប្រទេសអ្នកប្រកួតប្រជែង ដូចជា ចិន និង វៀតណាម ជាដើម មិនទាន់ទទួលសម្បទានបានច្រើនដូចកម្ពុជាទេ គឺបានន័យថា ក្នុងពេលបច្ចុប្បន្នកម្ពុជាមានឧត្តមភាពប្រៀបធៀប ។ ប៉ុន្តែឧត្តមភាពនឹងត្រូវបាត់បង់ នៅពេលដែលវៀតណាម និង ចិន មានកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលអំណោយផលដូចគ្នា (តារាង១) ។

ចិននឹងបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងពេលដ៏ឆាប់ ហើយ US ក៏អាចផ្តល់ឱ្យវៀតណាមឆាប់ដែរនូវលក្ខណៈសម្បត្តិជាប្រទេសមាន*ទំនាក់ទំនងពាណិជ្ជកម្មធម្មតា* ។ ចិនមានឧត្តមភាពប្រៀបធៀបរួចជាស្រេចនៅក្នុងផលិតកម្មសំលៀកបំពាក់ ដោយសារគេមានពលកម្មមានជំនាញខ្ពស់ជាង មានវត្ថុធាតុដើមតំលៃថោក និងមានសំភារៈបរិក្ខាទំនើបជាង ។ ពេលបានចូលជាសមាជិក WTO ចិននឹងអាចនាំចេញទៅទីផ្សារ US និង EU នូវផលិតផលមានគុណភាពខ្ពស់ជាងកម្ពុជា ។ ឯវៀតណាមក៏សំបូណ៌ពលកម្មមានជំនាញ និងមានតំលៃថោកដែរ ។ ដូច្នេះបើសិនចង់រក្សាសមត្ថភាពប្រកួតប្រជែងក្នុងពេលអនាគត កម្ពុជា ត្រូវតែរិះរកវិធីកាត់បន្ថយចំណាយទូទៅនៅក្នុងផលិតកម្មសំលៀកបំពាក់របស់ខ្លួន ។

## សន្និដ្ឋាន

***ការកែលំអបទបញ្ញត្តិរបស់រដ្ឋដែលទាក់ទងនឹងឧស្សាហកម្មកាត់ដេរ*** មានជាអាទិ ការសំអិតសំអាងនីតិវិធី សំរាប់ការផ្តល់អាជ្ញាប័ណ្ណឱ្យរោងចក្រ, ការនាំចូលវត្ថុធាតុដើម, និងការនាំចេញផលិតផលសំរេច, ដើម្បីជៀសវាងការឃឹតយ៉ាវ និងបន្ទុកមិនចាំបាច់ផ្សេងៗ ។ GMAC បានលើកថា ការកែលំអទាំងនេះនឹងជួយឱ្យឧស្សាហកម្មកាត់ដេរអាចឆ្លើយតបបានកាន់តែប្រសើរឡើងចំពោះតំរូវការផ្លាស់ប្តូរម៉ូដ, ក្រណាត់, ពណ៌... យ៉ាងឆាប់រហ័សរបស់អ្នកទិញ ហើយតាមនេះផលិតករក៏អាចកាត់បន្ថយតំរូវការស្តុកវត្ថុធាតុដើមទុកក្នុងចំនួនច្រើនៗបានដែរ ។

***ការដាក់អនុវត្តន៏ច្បាប់ការងារឱ្យបានតឹងរ៉ឹង*** វាមានសារៈសំខាន់ជាគន្លឹះសំរាប់ការកែលំអលក្ខខណ្ឌការងារនៅក្នុងឧស្សាហកម្មកាត់ដេរ ។ ការកែលំអទាំងនេះ នឹងញុំាងឱ្យមានកំលាំងពលកម្មមួយដែលមានសុខភាពល្អ និងមានផលិតភាពខ្ពស់ ។ វាបំពេញនូវការតំរូវផ្សេងៗរបស់ US ដើម្បីឈានទៅដល់ការតំឡើងកូតានាំចូលសំលៀកបំពាក់របស់កម្ពុជា ។ បរិស្ថានធ្វើការងារមានផលិតភាពខ្ពស់ នឹងអាចកើតមានឡើងផងដែរ តាមការពង្រឹងយន្តការដែលមានស្រាប់សំរាប់ការចរចាគ្នា រវាងអ្នកគ្រប់គ្រងរោងចក្រ សហជីព និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា, និងការពង្រឹងសមត្ថភាពរបស់អ្នកជាប់ពាក់ព័ន្ធទាំងនេះក្នុងការដោះស្រាយ

*(តទៅទំព័រទី ១៣...)*

# អ្នកភូមិជនជាតិដើមទំពួនសំរបខ្លួនទៅតាមការប្រែប្រួលសេដ្ឋកិច្ចដ៏ឆាប់រហ័ស

***ការបើកចំហសេដ្ឋកិច្ចតាំងពីទសវត្សរ៍១៩៩០ មានផលប៉ះពាល់យ៉ាងច្រើនដល់ខេត្តរតនៈគិរី ។ លោក John McAndrew ជាអ្នកជំនាញខាងមនុស្សសាស្ត្រ បានរាយការណ៍ពីលទ្ធផលនៃសិក្សាដល់ទីកន្លែងមួយដែលគាត់បានស្រាវជ្រាវក្នុងខែឧសភា ឆ្នាំ២០០០* ។***

ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ មានប្រជាជនកម្ពុជាកាន់តែច្រើនឡើងហើយ ដែលបានចាកចេញពីផ្ទះសំបែងរបស់ខ្លួន ដើម្បីទៅកាន់តំបន់មួយទៀតនៅក្នុងប្រទេស ។ ទោះបីក្នុងចលនាចំណាកស្រុកនេះ មួយចំនួនបានទៅកាន់ទីក្រុងនានា ដូចជា ភ្នំពេញជាដើម ប៉ុន្តែមួយភាគធំ (៥៧%) បានចាកចេញពី តំបន់ជនបទមួយ ដើម្បីទៅកាន់តំបន់ជនបទមួយទៀត[១] ។

តាមតួលេខរបស់រដ្ឋាភិបាល ក្នុងចន្លោះពេលពីឆ្នាំ១៩៩២ ដល់ ១៩៩៨ ខេត្តរតនៈគិរីមានកំណើនប្រជាជន លឿនជាងអត្រាកំណើនសំរាប់ទូទាំងកម្ពុជា ដោយឡែកបានលុងជាទីរួមខេត្តមានអត្រាកំណើនប្រជាជនខ្ពស់ជាងរាជធានីភ្នំពេញ[២] ទៅទៀត ។ មូលហេតុសំខាន់នៃកំនើនដ៏លឿននេះ គឺការចូលមកតាំងទីលំនៅនៃជនជាតិខ្មែរ ដែលធ្វើចំណាកស្រុកមកពីតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា ។

> ***តាមមតិរបស់មន្ត្រីនៅទីនោះនិយាយថា អត្រាកំណើនខុសគ្នានៃជនជាតិខ្មែរ នៅក្នុងស្រុកទាំងពីរ មានផលប៉ះពាល់ខុសគ្នាទៅលើភូមិនានា ។***

ដើម្បីពិនិត្យពីផលប៉ះពាល់នៃចំនាកស្រុក ជនជាតិខ្មែរចូលទៅក្នុងតំបន់ជនជាតិភាគតិច អ្នកស្រាវជ្រាវមួយក្រុមរបស់អង្គការសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍ និងសាមគ្គីភាព (CIDSE) កម្ពុជា បានទៅធ្វើការសិក្សាដល់ទីកន្លែងក្នុងខេត្តរតនៈគិរី នៅខែឧសភា ឆ្នាំ ២០០០ ។ ការសិក្សាបានធ្វើឡើងនៅក្នុងភូមិពីររបស់ជនជាតិភាគតិចទំពួន ដែលនៅទីនោះ ការលក់ដីធ្លី និងសកម្មភាពទីផ្សារ ទើបមានកំណើនឡើងក្នុងពេលថ្មីៗនេះ ។ ក្រុមស្រាវជ្រាវបានទៅស្នាក់នៅក្នុងភូមិទាំងពីរ និងបានធ្វើអង្កេតគ្រួសារលើ សំណាកគំរូជ្រើសតាមវិធីចៃដន្យដែលមានទំហំ ៥០% ។ ក្រុមអ្នកស្រាវជ្រាវក៏បានសំភាសន៍មន្ត្រីរដ្ឋាភិបាល អ្នកធ្វើការឱ្យ NGOs និងបានធ្វើអង្កេត ក្នុងទីផ្សារនានាដែលនៅជិតភូមិមុខសញ្ញា ។

ការសិក្សាបានរកឃើញថា ពីខែកញ្ញា ឆ្នាំ១៩៩៦ ដល់ ខែឧសភា ឆ្នាំ ២០០០ ចំនួនគ្រឹះស្ថានផ្សេងៗនៅផ្សារបានលុង បានកើន ៧៧% ដែលបកស្រាយពីកំណើនយ៉ាងលឿននៃសកម្មភាពទីផ្សារ[៣] ។ ការលូតលាស់នៃទីផ្សារក្នុងទីរួមខេត្តបានលុង បានជួយជំរុញដល់ការរីកលូតលាស់ទីផ្សារតាមស្រុក នៅស្រុកបរកែវ និងស្រុកអណ្តូងមាស ហើយក៏បានជះឥទ្ធិពលទៅលើភូមិទំពួនដែរ ។ សំណាកគំរូទាំងពីរ គឺមានភូមិកាហាល់ ដែលឋិតនៅតាមផ្លូវខេត្តចម្ងាយ ៤គ.ម ពីទីរួមស្រុកអណ្តូងមាស និងភូមិកាម៉ាង ដែលឋិតនៅតាមផ្លូវជាតិលេខ១៩ ជិតទីរួមស្រុកបរកែវ ។

## ការប្រែប្រួលបានចូលទៅដល់ភូមិកាហាល់ និងភូមិកាម៉ាង

ក្នុងឆ្នាំ១៩៩៤ អ្នកស្រាវជ្រាវម្នាក់បានកត់ត្រាថា ប្រជាជនស្រុកអណ្តូងមាស មាន ៥.៨៣១នាក់ ក្នុងនេះមានជនជាតិខ្មែរ ៥៤នាក់ ឯប្រជាជនស្រុកបរកែវមាន ៩,៣៨៦នាក់ ក្នុងនេះមានជនជាតិខ្មែរ ៣៥នាក់[៤] ។ នៅខែឧសភា ឆ្នាំ២០០០ អភិបាលស្រុកអណ្តូងមាសបានបង្ហាញបញ្ជីសំរង់ស្ថិតិប្រជាជនស្រុកអណ្តូងមាសថាមាន ៧.២០០នាក់ និងបានប៉ាន់ស្មានថា ក្នុងនេះមានជនជាតិខ្មែរប្រហែល ១០០នាក់ ។ អភិបាលស្រុកបរកែវ បានបង្ហាញបញ្ជីសំរង់ស្ថិតិប្រជាជនក្នុងស្រុកថា មាន ១២.០៦៩នាក់ និងបានប៉ាន់ស្មានថា ក្នុងនេះ មានជនជាតិខ្មែរជាង ១.០០០នាក់ ។

តាមមតិរបស់មន្ត្រីនៅទីនោះនិយាយថា អត្រាកំណើនខុសគ្នានៃជនជាតិខ្មែរនៅក្នុងស្រុកទាំងពីរ មានផលប៉ះពាល់ខុសគ្នាទៅលើភូមិនានា ។ នៅស្រុកអណ្តូងមាស កំណើនជនជាតិខ្មែរមានតិចតួចណាស់ ហើយប្រមូលផ្តុំ នៅក្នុងទីរួមស្រុក និងតំបន់ផ្សារ ។ នៅស្រុកបរកែវ ជនជាតិខ្មែរអ្នកចូលមក តាំងទីលំនៅមានចំនួនច្រើន ហើយក៏ប្រមូល ផ្តុំនៅតាមទីរួមស្រុក និងតាមតំបន់ផ្សារដូចគ្នា ។ ដោយសារចំនួនប្រជាជនជាជនជាតិខ្មែរ ចេះតែបន្តកើនឡើង ដីធ្លីកាន់តែច្រើនឡើង ក៏ត្រូវបានកាត់យកពីបណ្តាភូមិដែលនៅជាប់នឹងទីរួមស្រុកដូចជាភូមិកាម៉ាងជាដើម ដើម្បីស្រូបយកកំណើននេះ ។

ក្នុងខែឧសភា ឆ្នាំ២០០០ ក្រុមអ្នកស្រាវជ្រាវបានរកឃើញថា នៅផ្សារអូរកាប់ដ៏ឆ្ងាយដាច់ស្រយាលក្នុងស្រុកអណ្តូងមាស មានហាង ១០ ដែលជាកំណើនដ៏ច្រើន បើធៀបនឹងចុងឆ្នាំ១៩៩៦ ដែលមានតែ ៣ ហាងប៉ុណ្ណោះ ។ ហាងទាំងនេះ ភាគច្រើនគ្រប់គ្រងដោយគ្រួសារខ្មែរ ឬចារាយ/ខ្មែរ ។ ចំណុចគួរកត់សំគាល់មួយគឺ ភាគច្រើននៃម្ចាស់ហាងបានទិញដីនៅក្នុងស្រុក ដើម្បីដាំដំណាំសំរាប់លក់យកប្រាក់ ។ ក្នុងស្រុកបរកែវ ការលូតលាស់ក៏មានលំនាំប្រហែលគ្នានេះដែរ ប៉ុន្តែមានកំរិតធំជាងច្រើនណាស់ ។ នៅចុងឆ្នាំ១៩៩៦ ផ្សារបរកែវ មានហាងតែ ៤០ ទេ ហើយនៅខែឧសភា ឆ្នាំ២០០០ មានហាងដល់ទៅ ៨៤ (កំណើន ១១០%) ។ នៅឆ្នាំ២០០០ ក៏ដូចជាពីឆ្នាំ១៩៩៦ ដែរ ម្ចាស់ហាងជនជាតិខ្មែរបានគ្របដណ្តប់ក្តោបក្តាប់លើទីផ្សារ ឯជនជាតិដើមមិនទាន់មានហាងផ្ទាល់ខ្លួននៅឡើយទេ[៥] ។ ដល់ឆ្នាំ២០០០ ពួកម្ចាស់ហាងនៅផ្សារបរកែវ បានទិញដី ១៤០ហិកតារសំរាប់ដាំដំណាំលក់យកប្រាក់ ។

ក្រុមអ្នកស្រាវជ្រាវរបស់ CIDSE បានរកឃើញថា

* អត្ថបទនេះ គឺជាសេចក្តីសង្ខេបនៃរបាយការណ៍មួយដែលចុះផ្សាយក្នុងព្រឹត្តិប័ត្រ Bulletin of Concerned Asian Scholars, Vol. 32, No. 4: 39-51 ។ ការសិក្សានេះបាន ធ្វើឡើងដោយអង្គការ CIDSE-Cambodia ជាចំណែកមួយនៃកម្មវិធីអភិវឌ្ឍន៍សហគមន៍គ្រប់ជ្រុងជ្រោយ (ICD) របស់ខ្លួននៅក្នុងខេត្តរតនៈគិរី ។ លោក John McAndrew គឺជាទីប្រឹក្សានៅក្នុងកម្មវិធី ICD ខាងលើនេះ ។ ទស្សនៈនៅក្នុងអត្ថបទនេះ គឺជាគំនិតអ្នកនិពន្ធផ្ទាល់ ហើយមិនមែនជាទស្សនៈ រឺគំនិតរបស់ វបសអ ទេ ។

ល្បឿនលូតលាស់ខុសគ្នានៃទីផ្សារក្នុងស្រុកអណ្តូងមាស និងស្រុកបរកែវ បានជះឥទ្ធិពលមិនដូចគ្នាទេទៅលើភូមិផ្សេងៗ ជាពិសេសក្នុងបញ្ហាតំរូវការដីនៅលើទីផ្សារ ។ ភូមិកាហាល់ក្នុងស្រុកអណ្តូងមាស ធ្លាប់បានជាប់ពាក់ព័ន្ធជាមួយនឹងជនជាតិខ្មែរដែលមករកទិញដីនៅក្នុងតំបន់នោះ ។ ប៉ុន្តែដោយសារភូមិស្ថិតនៅជាប់នឹងផ្លូវខេត្ត និងនៅចម្ងាយ ៤គ.ម ពីទីរួមស្រុក ដូច្នេះតំរូវការដែលជំរុញឱ្យមានការលក់សិទ្ធិប្រើប្រាស់ដីមិនសូវមានច្រើនប៉ុន្មានទេ ។ ជាទូទៅភូមិកាហាល់ក្នុងពេលកន្លងមកមានលទ្ធភាពទប់ទល់បានយ៉ាងសក្តិសិទ្ធិ ចំពោះសកម្មភាពអ្នកក្រៅភូមិមកទិញដី ។ មកទល់សព្វថ្ងៃ ក្នុងចំណោម ៦៧គ្រួសារក្នុងភូមិ មិនទាន់មានគ្រួសារណាមួយដែលបានលក់សិទ្ធិប្រើប្រាស់ដីទេ ។ ក្នុងពេលដែលពួកអ្នកភូមិកំពុងស្វែងរកកុងសង់ស៊ុស (consensus) អំពីរបៀបរបបដែលត្រូវចាត់ចែងជាមួយប្រជាជនដែលនឹងអាចលក់ដីធ្លី អ្នកភូមិបានឯកភាពគ្នាថា

***ថ្វីត្បិតតែសេដ្ឋកិច្ចទីផ្សារបានរីកលូតលាស់យ៉ាងលឿនក៏ដោយ ក៏អ្នកស្រាវជ្រាវបានរកឃើញថា គ្រួសារប្រជាជននៅភូមិកាហាល់ និងកាម៉ាង នៅតែជាកសិករជីវព្រឹត្តិ ដែលចិញ្ចឹមជីវិត ដោយការកាប់ចំការ ដាំដំណាំ និងរកបំពេញបន្ថែម ដោយការ បេះប្រមូលផល ការប្រមាញ់ និងនេសាទ ។***

សិទ្ធិរបស់សហគមន៍ត្រូវមានអាទិភាពខ្ពស់ជាងគេនៅក្នុងការលក់ដូរដីធ្លីទាំងអស់ ។ ចាស់ទុំថ្នាក់ខ្ពស់ម្នាក់នៅក្នុងភូមិបាននិយាយយ៉ាងដាច់ណាត់ថា "ដីនៅក្នុងភូមិ គឺជាដីរួម ។ គេត្រូវប្រើប្រាស់វាសំរាប់បំរើគោលដៅរួម មិនមែនសំរាប់ផលចំណេញរបស់បុគ្គលទេ" ។

ប៉ុន្តែភូមិកាម៉ាងក្នុងស្រុកបរកែវ មានស្ថានភាពខុសប្លែកពីភូមិកាហាល់ ។ ដោយស្ថិតនៅតាមបណ្តោយផ្លូវជាតិ ជាប់នឹងទីរួមស្រុក និងទីតាំងផ្សារ ភូមិកាម៉ាង បានទទួលរងនូវសម្ពាធអោយមានការលះបង់សិទ្ធិលើដីធ្លីនៅក្នុងភូមិយ៉ាង ខ្លាំង ។ ការសិក្សាបានរកឃើញថា ក្នុងករណីភាគច្រើន ភូមិកាម៉ាងពុំមានលទ្ធភាពចាត់ចែងដោះស្រាយសំពាធផ្សេងៗ ដែលជាប់ទាក់ទិន នឹងទីផ្សារដីធ្លីឱ្យបានសក្តិសិទ្ធិទេ ។ មេភូមិ កាម៉ាង ដែលខ្លួនឯងបានលក់ដីមួយហិកតារក្នុងភូមិដែរនោះបាននិយាយថា អ្នកមាន ដីនៅតាមដងផ្លូវបានលក់ដីចេញពីព្រោះបារម្ភខ្លាចគេដកយកដោយគ្មានការ ទូទាត់សង ។ គាត់បានរាយការណ៍ថា ក្នុងចំណោម ៦៧គ្រួសារក្នុងភូមិ មាន៣៥គ្រួសារបានលក់សិទ្ធិប្រើប្រាស់ដី ហើយភាគច្រើនបានលក់ទៅឱ្យអ្នកទិញជាជនជាតិខ្មែរ ។ លើសពីនេះទៀត ដីសហគមន៍ចំនួន ១០០ហិកតារនៅក្នុងភូមិ ក៏ត្រូវបានគេលក់ដែរ ដោយបានប្រាក់ ២.៥០០ដុល្លារ ។ ដូចដីឯកជនដែរ ការលក់ដីសហគមន៍ ១០០ហិកតារនេះត្រូវបានធ្វើឡើង ដោយពុំមានការពិគ្រោះយោបល់ឱ្យបានពេញលេញជាមួយអ្នកភូមិទាំងអស់ទេ ។ ចាស់ទុំក្នុងភូមិម្នាក់បានបញ្ជាក់ពីការយល់ទាស់របស់គាត់ដូច្នេះថា "ប្រជាជនភូមិកាម៉ាងនឹងជួបការលំបាក បើសិនជាគេបន្តលក់ដី ពីព្រោះដីធ្លីកាន់តែតូចទៅៗ ឯប្រជាជនកាន់តែកើនច្រើនឡើងៗ ។ បើការលក់ដីចេះតែកើតមានជាបន្តទៀត អ្នកជំនាន់ក្រោយនឹងគ្មានដីដាំដំណាំទេ ។ ដូច្នេះតើពួកគេរកចិញ្ចឹមជីវិតឱ្យរស់បានយ៉ាងដូចម្តេចទៅ?"

## វិបាកនៃការប្រែប្រួល

នៅភូមិកាហាល់ និងកាម៉ាង រចនាសម្ព័ន្ធគ្រប់គ្រងក្នុងភូមិវាជាប់ទាក់ទងនឹងចាស់ទុំ, មេភូមិ, និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ, ដែលបំពេញ តួនាទីដឹកនាំផ្សេងៗ ។ ការសិក្សាបានរកឃើញថា ស្ត្រីជាសមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ មានតួនាទីបន្ទាប់បន្សំក្នុងការធ្វើសេចក្តីសំរេចនៅក្នុង ភូមិ ។ ការធ្វើសមាហរណកម្មកាន់តែច្រើនជាមួយសង្គមធំខាងក្រៅភូមិនៅក្រោមកំលាំងជំរុញនៃសេដ្ឋកិច្ចទីផ្សារ បានធ្វើឱ្យអំណាចរបស់ចាស់ទុំថមថយចុះ នៅចំពោះមុខវត្តមាននៃអ្នកដឹកនាំក្មេងៗដែលចេះអក្សរខ្មែរ ។

មួយចំណែកទៀត ទោះបីទំរង់ដើមមានលក្ខណៈប្រហាក់ប្រហែលគ្នាក៏ដោយ ក៏រចនាសម្ព័ន្ធគ្រប់គ្រងនៃភូមិទាំងពីរហាក់ដូចមានការវិវត្តន៍ខុសគ្នា ។ រចនាសម្ព័ន្ធនេះ បានឆ្លុះបញ្ចាំងក្នុងកំរិតណាមួយនូវបុគ្គលិកលក្ខណៈខុសៗគ្នានៃថ្នាក់ដឹកនាំក្នុងភូមិនិមួយៗ ។ ដោយឡែកនៅភូមិកាម៉ាង សកម្មភាពលក់ដីធ្លីបានធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ប្រពៃណីនៃការធ្វើសេចក្តីសំរេចតាមការមូលមតិគ្នា ។

នៅភូមិកាហាល់ ការសិក្សាបានរកឃើញថា ថ្នាក់ដឹកនាំតែងពិគ្រោះក្នុងចំណោមគ្នាគាត់ និងពិគ្រោះជាមួយភូមិទាំងមូលផងដែរ ។ ជាលទ្ធផលអ្នកចាស់ទុំក្នុងភូមិ ត្រូវបានគេបញ្ចូលទៅក្នុងការធ្វើសេចក្តីសំរេច ហើយជាទូទៅ

**តារាង១ វិធីសាស្ត្រចិញ្ចឹមជីវិត គិតតាមគ្រួសារ ខែឧសភា ២០០០**

| | ភូមិកាហាល់ | ភូមិកាម៉ាង |
|---|---|---|
| ធ្វើចំការ | 34 | 34 |
| ដាំស្រូវស្រែ | 6 | 0 |
| ចិញ្ចឹមជ្រូក | 27 | 22 |
| ចិញ្ចឹមមាន់ | 29 | 17 |
| បេះប្រមូលផលពីព្រៃ | 33 | 34 |
| បរបាញ់ ដាក់អន្ទប់/អន្ទាក់ | 27 | 28 |
| នេសាទ | 33 | 27 |
| ផលិត និងលក់ទំនិញ | 7 | 9 |
| ទិញ និងលក់ទំនិញ | 2 | 5 |
| ការងារយកប្រាក់ឈ្នួល | 14 | 28 |

*n = 34 សំរាប់ភូមិនិមួយៗ*

អ្នកដឹកនាំទាំងអស់តែងចាត់ទុកខ្លួនឯងថា មានការទទួលខុសត្រូវនៅចំពោះមុខប្រជាជន ។ ដោយសាររវាងអ្នកដឹកនាំភូមិ គេឃើញមានអន្តរកម្មយ៉ាងជិតស្និទ្ធ និងការគោរពគ្នាទៅវិញទៅមក ភូមិកាហាល់ហាក់មានលទ្ធភាពអាចចាត់ចែងបានយ៉ាងសក្តិសិទ្ធនូវបញ្ហាខាងដីធ្លីដែលផុសឡើង ដូចជាទំនាស់ជាភូមិជិតខាងមួយពីរឿងដីស្រែទំនាបមួយកន្លែងជាដើម ។

នៅភូមិកាម៉ាង ប្រធានភូមិបាន ប្រមូលផ្តុំអំណាចមកលើខ្លួនគាត់ព្រមទាំង បានរិតត្បិតឥទ្ធិពលរបស់អ្នកដទៃ ។ ជាលទ្ធផល អ្នកចាស់ទុំត្រូវគេផាត់ចេញពីការពិភាក្សាគ្នា ហើយពួកអ្នកដឹកនាំមិនបានធ្វើការពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយប្រជាជនទេ ។ ជំហរនេះបានធ្វើឱ្យចុះខ្សោយដល់វិធីសាស្ត្រធ្វើសេចក្តីសំរេចជារួមដែលជាប្រពៃណីរបស់ភូមិទំពួននានាតាំងពីច្រើនជំនាន់មកហើយ ។ វាក៏បានបង្កើននូវការមិនទុកចិត្តគ្នា និងការគុំគួនគ្នាក្នុងចំណោមអ្នកភូមិជាច្រើននាក់ ។ នៅកាម៉ាងរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងភូមិ ពុំមានលទ្ធភាពចាត់ចែងការងារឱ្យបានសក្តិសិទ្ធទេ នៅចំពោះមុខកំលាំងផ្សេងៗដែលកំពុងរុញច្រានទីផ្សារដីធ្លី ។

ថ្វីត្បិតតែសេដ្ឋកិច្ចទីផ្សារបានរីកលូតលាស់យ៉ាងលឿនក៏ដោយ ក៏អ្នកស្រាវជ្រាវបានរកឃើញថា គ្រួសារប្រជាជននៅភូមិកាហាល់ និងកាម៉ាង នៅតែជាកសិករជីវព្រឹត្តិ (subsistence cultivators) ដែលចិញ្ចឹមជីវិតដោយការកាប់ចំការ ដាំដំណាំ និងរកបំពេញបន្ថែមដោយការបេះប្រមូលផលការប្រមាញ់ និងនេសាទ ។ មកដល់ខែឧសភា ឆ្នាំ២០០១ ការលក់សិទ្ធិប្រើប្រាស់ដីជាច្រើនក្នុងភូមិកាម៉ាង មិនទាន់មានផលប៉ះពាល់គួរឱ្យកត់សំគាល់នៅឡើយទេ ទៅលើជីវភាពរស់នៅរបស់អ្នកភូមិ ពីព្រោះដីដែលគេបានលក់សិទ្ធិប្រើប្រាស់ ភាគច្រើន គឺជាដីចំការទុកទំនេរចោលដោយមិនទាន់គ្រប់ឆ្នាំ អាចធ្វើការដាំដុះម្តងទៀតបាន ។ ដូចគ្នាដែរ ការបើកចំហតំបន់ព្រៃឱ្យធ្វើការដាំដុះមិនទាន់មានផលប៉ះពាល់អវិជ្ជមាននៅឡើយទេ ទៅលើទិន្នផលផលិតផលស្បៀងអាហារដែលរកបានពីការបេះនិងប្រមាញ់ ប៉ុន្តែទិន្នផលនេះ នឹងត្រូវថយចុះក្នុងពេលខាងមុខ ។ មួយចំណែកទៀត ទោះបីស្ថិតនៅជិតទីផ្សារក៏ដោយ ក៏មានគ្រួសារកាម៉ាងតិចតួចណាស់ដែលបានក្លាយជាអាជីវករ ឬអ្នកលក់ដូរ ។ ប៉ុន្តែមានគ្រួសារកាម៉ាងមួយចំនួនធំ អាចរកចំណូលបានពីពលកម្មយកប្រាក់ឈ្នួលដែលភាគច្រើនជាការងារកសិកម្មតាមរដូវកាល ។

> ***ដើម្បីគាំទ្រដល់ជនជាតិដើម អ្នកអនុវត្តការងារអភិវឌ្ឍន៍ និងអ្នកកសាងគោលនយោបាយ ត្រូវតែជួយដល់ប្រជាជនតំបន់ខ្ពង់រាបទាំងនេះ ក្នុងការរក្សាការពារ-សិទ្ធិកាន់កាប់ដីធ្លី ។ ការក-សាងច្បាប់ដីធ្លីដ៏ខ្លាំងមួយ វានឹងជួ-យទ្រទ្រង់ដល់ការងារនេះ ។ ការអនុម័តច្បាប់ជាបណ្តើរៗ និងឱ្យបានគ្រប់ជ្រុងជ្រោយ នឹងផ្តល់នូវក្របខ័ណ្ឌច្បាប់សំរាប់ដោះស្រាយករ***

ដូចការរំពឹងទុក គ្រួសារក្នុងភូមិកាហាល់មមាញឹកជាខ្លាំងនៅក្នុងការងារធ្វើចំការ និងក្នុងសកម្មភាពបេះប្រមូលផលប្រមាញ់ និងនេសាទ ។ ប្រការគួរអោយកត់សំគាល់មួយគឺ គ្រួសារជាច្រើនក្នុងភូមិកាហាល់ មាន ចិញ្ចឹមមាន់ និងជ្រូក សំរាប់លក់អោយឈ្មួញកណ្តាលខ្មែរ ដែលតែងចូលទៅរកទិញដូរ តាមភូមិយ៉ាងទៀងទាត់ ។ ចំណុចគួរឱ្យកត់សំគាល់មួយទៀត គឺចំនួនដ៏ច្រើននៃគ្រួសារក្នុងភូមិកាហាល់ដែលរកចំណូលបានពីការងារពលកម្មស៊ីប្រាក់ឈ្នួល ទោះបីភាគច្រើន គឺជាការងារក្នុងកសិដ្ឋានមានរយៈពេលខ្លីក៏ដោយចុះ (តារាង១) ។

ជាទូទៅ គ្រួសារនានានៅកាម៉ាង គេចូលរួមក្នុងសកម្មភាពទីផ្សារច្រើនជាងគ្រួសារនៅភូមិកាហាល់ ។ ប៉ុន្តែ ក្រៅពីការលក់ដីធ្លីចេញ លក្ខណៈខុសគ្នាមិនជាលេចធ្លោដូចការរំពឹងទុកនោះទេ ។ មួយចំណែកទៀត ចំនួនដ៏ច្រើននៃគ្រួសារក្នុងភូមិនីមួយៗដែលចូលរួមក្នុងការទិញ និងលក់ទំនិញ (តារាង២) បានបង្ហាញឱ្យឃើញថា មានការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចទីផ្សារមួយក៏រីតហើយ ។ ចំណុចគួរអោយកត់សំគាល់មួយ គឺចំនួនដ៏ច្រើននៃគ្រួសារក្នុងភូមិទាំងពីរ ដែលបានលក់ផលដំណាំសំរាប់លក់យកប្រាក់ ព្រមទាំងលក់ផលព្រៃឈើ ។ រឿងនេះ វាបញ្ជាក់ពីសារៈសំខាន់នៃចីរភាពធនធានធម្មជាតិ ចំពោះជីវភាពរស់នៅរបស់អ្នកភូមិ ។ ការថយចុះទិន្នផលបានមកពីដីចំការ ព្រៃ ស្ទឹង អូរ វាធ្វើអោយប្រាក់ចំណូលបានមកពីទីផ្សារថយចុះ ។ ក្នុងពេល ជាមួយគ្នានេះដែរ កំណើននៃការលក់ស្បៀងអាហារដែលអ្នកភូមិ បានដាំ ឬបេះ ដើម្បីយកទៅទិញផលិតផលកម្មន្តសាលផ្សេងៗ អាច មានផលប៉ះពាល់មិនល្អចំពោះកិរិតអាហារូបត្ថម្ភ និងសុខភាពរបស់អ្នកភូមិ ។

**តារាង២ ការរួមសកម្មភាពទីផ្សារ តាមគ្រួសារ* ឧសភា ២០០០**

| | ភូមិកាហាល់ | | ភូមិកាម៉ាង | |
|---|---|---|---|---|
| | ទិញ | លក់ | ទិញ | លក់ |
| ដី | 1 | 0 | 0 | 4** |
| ពលកម្ម | *** | 14 | *** | 28 |
| ស្រូវអង្ករ | 15 | 6 | 12 | 12 |
| ដំណាំលក់យកប្រាក់ | 12 | 16 | 12 | 22 |
| គោក្របី | 5 | 3 | 2 | 6 |
| ជ្រូក | 14 | 11 | 17 | 10 |
| ផលព្រៃឈើ | 3 | 11 | 10 | 15 |

n = 34 *សំរាប់ភូមិនិមួយៗ*

* *ទិន្នន័យស្តីពីការទិញ-លក់ដីបានស្រង់សំរាប់ប្រាំឆ្នាំកន្លងទៅ ប៉ុន្តែទិន្នន័យស្តីពីការទិញ-លក់ទំនិញផ្សេងទៀត បានស្រង់សំរាប់តែមួយឆ្នាំមុនប៉ុណ្ណោះ ។*

** *មានតែបួនគ្រួសារសំណាកគំរូប៉ុណ្ណោះដែលបានទទួលស្គាល់ថា បានលក់ដី ។ ប៉ុន្តែនៅពេលយើងសួរមេភូមិពីគ្រួសារដែលបានលក់ដី គាត់បញ្ជាក់ថា មាន ១៩គ្រួសារនៅក្នុងសំណាកគំរូ ។ តបនឹងសំនួរដដែលនេះ ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបានឆ្លើយថា មាន ១៣គ្រួសារនៅ ក្នុងសំណាកគំរូ ។*

*** *នៅក្នុងអង្កេត គ្មានសំនួរចំៗពីការទិញពលកម្មទេ ។*

ការសិក្សាបានឃើញថា មានការលក់ពលកម្មយ៉ាងច្រើននៅភូមិកាម៉ាង និងមាន ច្រើនគួរសមនៅភូមិកាហាល់ ។ ប៉ុន្តែប្រាក់ចំណូលបានមកពីការលក់កំលាំងពលកម្ម ជាទូទៅមានកំរិតទាប ។ បើសិនជាធ្វើការប្រៀបធៀប ការប្រវាសពលកម្មគ្នាក្នុង ការងារធ្វើចំការ ត្រូវបានអនុវត្តដោយគ្រួសារភាគច្រើននៅក្នុងភូមិទាំងពីរ ហើយការធ្វើចំការនេះ នៅតែជាប្រភពចំបងនៃការរកចិញ្ចឹមជីវិតនៅឡើយ ។ សេដ្ឋកិច្ចទីផ្សារបានហូរចូលមកក្នុង ភូមិកាម៉ាង និងភូមិកាហាល់ហើយៗពួកអ្នកភូមិក៏បានចូលរួមតាមនោះដែរ ប៉ុន្តែវាមិនទាន់បានធ្វើឱ្យអ្នកភូមិភាគច្រើន គេចផុតពីស្ថានភាពជាកសិករជីវព្រឹត្តិនៅឡើយទេ ។

## ផលចំណេញខាងគោលនយោបាយ និង ការអនុវត្តន៍

លទ្ធផលនៃការសិក្សានៅភូមិកាហាល់ និងកាម៉ាង វាជាប្រយោជន៍ដល់អ្នកអនុវត្តការងារអភិវឌ្ឍន៍ និងអ្នកកសាងគោលនយោបាយ ។ យើងបាន ពិនិត្យឃើញថា ការរីកដុះដាលនៃសេដ្ឋកិច្ចទីផ្សារបានបង្កនូវផលវិបាកដល់ភូមិទាំងពីរ ប៉ុន្តែឥទ្ធិពលយូរអង្វែងរបស់វា យើងពុំទាន់ដឹងនៅឡើយទេ ។ ដូច្នេះវាមិនសមរម្យទេ បើសិនធ្វើការអះអាងនៅពេលនេះថា សេដ្ឋកិច្ចទី ផ្សារបានបង្កតែភាពអន្តរាយដល់ភូមិទាំងពីរ ។ កន្លងមក ប្រជាជនទាំងពីរ ភូមិបានផុសផុលចូលរួម ទាញយកអត្ថប្រយោជន៍ពីការលូតលាស់ទីផ្សារនៅ ក្នុងមូលដ្ឋាន ។ តាមការចិញ្ចឹមជ្រូក មាន់ ការដាំដំណាំលក់យកប្រាក់ និងការ បរបាញ់សត្វព្រៃ ពួកអ្នកភូមិអាចដូរ ឬទិញផលិតផលកម្មន្តសាលដែលខ្លួន ចង់បាន ។ តាមរយៈការងារយកប្រាក់កំរៃប្រចាំថ្ងៃដែលមានធ្វើម្តងម្កាល អ្នកភូមិក៏អាចរកចំណូលមកបំពេញតំរូវការក្នុងជីវភាពរស់នៅដែរ ។ ដោយសារបានរស់នៅជិតផ្លូវ និងទីរួមស្រុក អ្នកភូមិក៏អាចទាញយកអត្ថប្រយោជន៍ថែមទៀតពីគំរោងអភិវឌ្ឍន៍ផ្សេងៗរបស់រដ្ឋាភិបាល និង NGOs ។ ការប្រែប្រួលផ្សេងៗដែលកើតចេញពីការមានផ្លូវថ្នល់ល្អជាងមុន និងការលូតលាស់ខាងពាណិជ្ជកម្ម ហាក់ដូចជាមានផលប៉ះពាល់អវិជ្ជមានតិចតួចទេ ចំពោះរបៀបរបបរស់នៅដ៏ល្អប្រពៃរបស់ជនជាតិដើម ។

ប៉ុន្តែការសិក្សាបានរកឃើញដែរថា កំលាំងទីផ្សារដែលកំពុងដំណើរការនៅក្នុងខេត្តរតនៈគីរី ក៏មានសក្តានុពលអាចធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់សុខុមាលភាពរបស់សហគមន៍ជនជាតិដើមបានដែរ ។ គុណវិបត្តិនេះគេអាចមើលឃើញយ៉ាងច្បាស់នៅក្នុងករណីសិក្សាភូមិកាម៉ាង ។ នៅក្នុងភូមិនេះ សេដ្ឋកិច្ចទីផ្សារ ពិសេសទីផ្សារដីធ្លី បានធ្វើឱ្យខូចខាតយ៉ាងខ្លាំងដល់រចនាសម្ព័ន្ធគ្រប់គ្រង និងសាមគ្គីភាពក្នុងសហគមន៍ ។ ការលក់ដីធ្លីក្នុងភូមិ មិនគ្រាន់តែបានកាត់បន្ថយធនធានធម្មជាតិដ៏ចាំបាច់ សំរាប់ទ្រទ្រង់ជីវភាព ប៉ុណ្ណោះទេ ប៉ុន្តែបានធ្វើឱ្យខូចខាតដល់ធនធានខាងវប្បធម៌ និងសង្គមកិច្ចដ៏សំខាន់ សំរាប់ចាត់ចែងដោះស្រាយបញ្ហាចាំបាច់ផ្សេងៗដែលផុសចេញពីការប្រែប្រួល ។ តាមការប្រៀបធៀបករណីសិក្សាភូមិកាហាល់បានបង្ហាញពីវិធីដែលភូមិមួយ ព្រមគ្នានឹងការជំទាស់ជាសមូហភាពចំពោះការលក់ដីធ្លីអាចកសាងបាននូវរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់មូលដ្ឋានដ៏មានសមត្ថភាព និងរក្សាគាំពារបាននូវកិច្ចសហប្រតិបត្តិការគ្នានៅក្នុងសហគមន៍ ។

ទាក់ទងនឹងការលក់ដីធ្លី ការសិក្សានេះបានផ្តល់ចម្លើយមួយយ៉ាងច្បាស់លាស់ ។ ដើម្បីគាំទ្រដល់ជនជាតិដើម អ្នកអនុវត្តការងារអភិវឌ្ឍន៍ និងអ្នក កសាងគោលនយោបាយ ត្រូវតែជួយដល់ប្រជាជនតំបន់ខ្ពង់រាបទាំងនេះ ក្នុងការរក្សាការពារសិទ្ធិកាន់កាប់ដីធ្លី ។ ការ កសាងច្បាប់ដីធ្លីដ៏ខ្លាំងមួយ វានឹងជួយ ទ្រទ្រង់ដល់ការងារនេះ ។ ការអនុម័តច្បាប់ជាបណ្តើរៗ និងឱ្យបានគ្រប់ជ្រុងជ្រោយ នឹងផ្តល់នូវក្របខ័ណ្ឌច្បាប់ សំរាប់ដោះស្រាយករណីទន្ទ្រានយកដីផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងជនជាតិដើម ។ ប៉ុន្តែវិធានការខាងលើនេះ អាចដោះស្រាយបញ្ហាបានតែមួយចំណែកទេ ។ សំខាន់ប្រព័ន្ធតុលាការកម្ពុជាត្រូវតែពង្រឹងថែមទៀត មុននឹងអាចធានាជូនជនជាតិដើមបាននូវកិច្ចការពារដ៏សមស្របមួយនៅក្រោមច្បាប់រដ្ឋ ។ គឺបានន័យថា សហគមន៍ជនជាតិដើម ត្រូវតែក្តាប់សិទ្ធិអំណាចរបស់ខ្លួន និងលើកស្ទួយសិទ្ធិរបស់ខ្លួន ។ អ្នកធ្វើការងារអភិវឌ្ឍន៍គឺមានស្ថានភាពល្អ ដើម្បីជួយទ្រទ្រង់ដល់ការខំប្រឹងប្រែងនេះ ទោះបីក្នុងករណីជាច្រើន គេត្រូវធ្វើការផ្លាស់ប្តូរជា យុទ្ធសាស្ត្រនូវចំណុចយកចិត្តទុកដាក់ក៏ដោយ ។ ជាញឹកញាយណាស់ ទីភ្នាក់ងារអភិវឌ្ឍន៍នានាតែងចាត់ទុកថា សហគមន៍មានលទ្ធភាពប្រើប្រាស់ធនធាន ធម្មជាតិ និងមានសន្តិសុខក្នុងការកាន់កាប់ដីធ្លីគ្រប់គ្រាន់ហើយ ប៉ុន្តែជាក់ស្តែងគេពុំមានស្ថានភាពល្អដូច្នេះទៀតទេ ។

***ការអនុម័តច្បាប់ជាបណ្តើរៗ និងឱ្យបានគ្រប់ជ្រុងជ្រោយ នឹងផ្តល់នូវក្របខ័ណ្ឌច្បាប់សំរាប់ដោះស្រាយករណីទន្ទ្រានយក-ដីផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងជនជាតិដើម ។ ប៉ុន្តែវិធាន ការខាងលើនេះ អាចដោះស្រាយបញ្ហាបានតែមួយចំណែកទេ ។ សំខាន់ប្រព័ន្ធតុលាការកម្ពុជាត្រូវតែពង្រឹងថែមទៀត មុននឹងអាច***

ដោយសារហេតុផលដូចខាងលើ អង្គការអភិវឌ្ឍន៍នានាដែលធ្វើការងារជាមួយជនជាតិដើម ត្រូវតែធ្វើសកម្មភាពទាំងឡាយខាងការធ្វើផែនទីនៃការប្រើប្រាស់ដី ការធ្វើផែនការ និងការគ្រប់គ្រង ជាបន្ថែមទៅលើគំរោងខាងហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន កសិកម្ម សុខាភិបាល និងអប់រំ ។ ដូចគ្នាដែរ អាជ្ញាធរនៅកំរិតឃុំ ស្រុក និងខេត្ត ត្រូវតែទទួលស្គាល់ និងជួយទ្រទ្រង់ដល់ការព្រមព្រៀងផ្ទៃក្នុងនានា ដែលសហគមន៍ជនជាតិដើមប

# សម្រែកអ្នកលក់ដូរតូចតាច

***ស្ត្រីអ្នកលក់ដូរតូចតាចនៅតាមផ្សារនានាក្នុងក្រុងភ្នំពេញ មានជីវភាពលំបាកខ្លាំងណាស់ ។ អត្ថបទនេះបង្ហាញពី លទ្ធផលនៃការសិក្សាអំពីតម្រូវការរបស់អ្នកលក់ដូរតូចតាច និងអំពីកម្មវិធីនានា ដែលត្រូវបានកសាងឡើងដើម្បីផ្តល់សិទ្ធិអំណាចឱ្យពួកគេ * ។***

## កម្មវិធី WELR

ក្នុងរដូវក្តៅឆ្នាំ១៩៩៧ កម្មវិធីសេដ្ឋកិច្ច និងសិទ្ធិតាមផ្លូវច្បាប់របស់ស្ត្រីនៃអង្គការមូលនិធិអាស៊ី (Asia Foundation's Women's Economics and Legal Rights: WELR) បានចាប់ផ្តើមគំរោងមួយរយៈបួនឆ្នាំនៅក្នុងប្រទេសកម្ពុជាដើម្បីលើកទឹកចិត្តស្ត្រីអ្នកលក់ដូរតូចតាច ឱ្យធ្វើការងាររួមសហការគ្នាដើម្បីកែលំអកំរិតប្រាក់ចំណូល និងស្ថានភាពធ្វើការងារ ។ ស្ត្រីទាំងនេះស្ថិតនៅស្រទាប់ក្រោមនៃវិស័យពាណិជ្ជកម្មនៅកម្ពុជា ហើយក្រីក្រខ្លាំងណាស់មិនអាចជួលតូបលក់នឹងគេបានទេ ។ ដូច្នេះហើយគាត់លក់តាមកញ្ច្រែពាង ហើយជាញឹកញយត្រូវលក់នៅតាមកន្លែងអន់ៗបំផុតនៅក្នុងផ្សារ ។

សំភាសន៍ពីដំបូងៗ ដែលអ្នកស្រាវជ្រាវ WELR បានធ្វើឡើងក្នុងឆ្នាំ១៩៩៧ បានបង្ហាញថា ភាពក្រីក្របានសង្កត់ធ្ងន់ខ្លាំងណាស់ទៅលើស្ត្រីអ្នកលក់ដូរទាំងនេះ ។ កង្វះខាតមធ្យោបាយធានារ៉ាប់រងជីវិត ដូចជាស្បៀងអាហារ ទឹក និងជំរកជាដើម បានពង្រឹងជំនឿថា "ការលំបាកវេទនា គឺជាព្រេងវាសនា" ។ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ ស្ត្រីអ្នកលក់ដូរ មានជំនឿអំពីអនាគតកាលដ៏ល្អ ហើយបានខិតខំផ្តល់ឱ្យកូនចៅខ្លួននូវ "គ្រឿងប្រណិតៗ" ដូចជាការអប់រំ ការថែទាំសុខភាព និង តំរូវការជាមូលដ្ឋានមួយចំនួនខាងសិទ្ធិមនុស្ស ។

ការសិក្សាបានរកឃើញថា ជារឿយៗស្ត្រីអ្នកលក់ដូរតូចតាច ទាំងអ្នកមានគ្រួសារ និងអ្នកនៅលីវ គឺជាអ្នករកចំណូលតែម្នាក់គត់នៅក្នុងគ្រួសារ ហើយក្រៅពីការលក់ដូរជាច្រើនម៉ោងនៅឯផ្សារ គាត់ត្រូវធ្វើការងារផ្ទះអស់ច្រើនម៉ោងថែមទៀត ។ សំរាប់ការងារដ៏លំបាកលំបិននេះ អ្នកស្រាវជ្រាវរកឃើញថា ជាទូទៅ ពួកគាត់រកចំណូលបានតិចជាងមួយដុល្លារក្នុងមួយថ្ងៃ ហើយជួនកាលគាត់ត្រូវដកចំណូលនេះទៅបង់ផាក ឬបង់ពន្ធផ្សេងៗតាមការតំរូវទៀតផង ។

ការផ្តួចផ្តើមធ្វើគំរោងជួយដល់ស្ត្រីអ្នកលក់ដូរតូចតាច គឺជាបញ្ហាប្រឈមមួយសំរាប់ WELR ពីព្រោះស្ត្រីទាំងនេះមិនធ្លាប់មានបទពិសោធន៍ធ្វើការរួមគ្នាពីមុនមកទេ ហើយក៏មិនបានយល់ឃើញគ្រប់គ្នាទេថា ខ្លួនគាត់គឺជាសមាជិកម្នាក់នៃក្រុមមួយធំ ដែលមានចំណងផ្សារភ្ជាប់គ្នា និងមានលក្ខណៈគ្រប់ជ្រុងជ្រោយនោះទេ ។ ការសិក្សា WELR បានរកឃើញថា អ្នកលក់ដូរឯករាជ្យទាំងនេះច្រើនតែគិតថាខ្លួនគាត់ជាប្រភេទមនុស្សឯករាជ្យ ។ ម្យ៉ាងទៀតក៏គ្មានអ្នកណាដែលអាចដឹកនាំការងារចងគ្នាជាក្រុមនោះដែរ ។ ឧទាហរណ៍ល្អៗបំផុតនៃកម្មវិធីផ្តល់សិទ្ធិអំណាច និងលើកកំពស់សុខុមាលភាពសេដ្ឋកិច្ចរបស់ស្ត្រី ដូចជាសមាគមស្ត្រីអ្នកផ្តល់អាជីពដោយខ្លួនឯង (Self-employed Women's Association: SEWA) នៅប្រទេសឥណ្ឌា និង Banchte Shekha នៅប្រទេសបង់ក្លាដេសជាដើម សុទ្ធតែត្រូវបានកសាង និងដឹកនាំឡើងដោយសកម្មជនក្នុងស្រុកដែលមានឧត្តមគតិខ្ពស់ ហើយដែលបានបូជាជីវិតខ្លួនទាំងមូលចំពោះការងារនេះ ។

មុនចាប់ផ្តើមកម្មវិធី WELR មានការធ្វើសំភាសន៍យ៉ាងទូលំទូលាយ និងជាប្រព័ន្ធជាមួយក្រុមមន្ត្រីរដ្ឋាភិបាល ដែលគ្រប់គ្រងដំណើរការនៃផ្សារ (ហៅថាគណៈកម្មាធិការផ្សារ), ស្ត្រីអ្នកលក់ដូរតូចតាច ៨៩នាក់, និង NGOs មួយចំនួន (ក្នុងនេះមានអង្គការមួយដែលមូលនិធិអាស៊ី សង្ឃឹមថានឹងទទួលយកគំរោងទៅអនុវត្តបន្ត) ។ របាយការណ៍ស្តីពីការស្រាវជ្រាវដើម្បីធ្វើសកម្មភាព និងកម្មវិធីនានាដែលផុសចេញមក ត្រូវបានចុះផ្សាយដោយមូលនិធិអាស៊ីនៅក្នុងឯកសារមួយ ដែលមានចំណងជើងថា សម្រែកអ្នលលក់ដូរតូចតាច (Vendors' Voices) ។

ក្នុងពេលធ្វើការស្រាវជ្រាវ បុគ្គលិក WELR បានចុះជាប់រាល់ថ្ងៃ និងអស់រយៈពេលជាច្រើនខែ នៅក្នុងផ្សារទាំងពីរដែលត្រូវសិក្សា ។ នៅក្នុងរបាយការណ៍ អ្នកស្រាវជ្រាវបានលើកថា ការជួបប្រាស្រ័យជិតស្និទ្ធបែបនេះមាន សារៈសំខាន់បំផុតដើម្បីកសាងទំនាក់ទំនង ទំនុកចិត្ត និងគ្រឹះដ៏ចាំបា

**តារាង ១. បញ្ហាផ្សេងៗនៅតាមទីផ្សារ**

| | ដើមគរ | ច្បារអំពៅ | មធ្យមភាគសរុប |
|---|---|---|---|
| លទ្ធភាពខ្ចីឥណទាន/បំណុល | 45.2 | 42.6 | 43.9 |
| សុខភាព និងអនាម័យ | 31 | 34 | 32.5 |
| របររកស៊ីមិនអំណោយផល | 26.2 | 23.4 | 24.8 |
| កន្លែងលក់ដូរនៅក្នុងផ្សារ | 31 | 19.1 | 25.05 |
| ការថែទាំកូន | 16.7 | 23.4 | 20.05 |
| ជីវភាពរស់នៅ | 14.3 | 25.5 | 19.9 |
| សន្តិសុខស្បៀង | 9.5 | 19.1 | 14.3 |
| ខ្វះការឧបត្ថម្ភពីសហព័ទ្ធ | 9.5 | 8.5 | 9 |
| ពន្ធដារផ្សេងៗ | 4.8 | 0 | 2.4 |
| ទឹកលិច | 0 | 2.1 | 1.05 |
| ក្លិនស្អុយ | 0 | 2.1 | 1.05 |
| ការដឹកជញ្ជូន | 2.4 | 0 | 1.2 |
| ហិង្សាក្នុងគ្រួសារ | 2.3 | 0 | 1.15 |

*ប្រភព: សំរែកអាជីវករ ឆ្នាំ២០០១*

* កម្មវិធី WELR ទទួលមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងត្រូវបានបង្កើតឡើងដើម្បីលើកកំពស់សិទ្ធិពលករជាស្ត្រីភេទទាំងនៅក្នុងវិស័យផ្លូវការ និងក្រៅផ្លូវការនៅតាមប្រទេសផ្សេងៗនៅអាស៊ី ។ ក្រៅពីកម្ពុជា កម្មវិធី WELR បានដំណើរការនៅប្រទេសណេប៉ាល់ បង់ក្លាដេស និងស៊ីរីលង្កា ។ ឯកសារ Vendors' Voices: The Story of Women Micro-Vendors in Phnom Penh Markets and an Innovative Program Designed to Enhance Their Lives and Livelihoods, ដែលសរសេរឡើងដោយ Suzanna Stout Banwell អាចស្វែងរកបានពីអង្គការមូលនិធិអាស៊ីនៅភ្នំពេញ ។ គំនិត ដើមហេតុ និងមតិទាំងអស់ដែលចុះ នៅក្នុងអត្ថបទនេះជារបស់អ្នក

ាច់ផ្សេងៗ សំរាប់ដំណើរការកសាងកម្មវិធី ។ បើសិនគ្មានការស្រឡាញ់រាប់អានគ្នាបែប នេះទេ បុគ្គលិក WELR បានបញ្ជាក់ថា ពួកខ្លួនមិនអាចធ្វើការកើតនៅក្នុង បរិស្ថានដ៏ពិបាកដូច្នេះទេ ។

## ទីផ្សារមុខសញ្ញានៅក្នុងគំរោង

កម្មវិធី WELR ផ្តោតលើផ្សារលក់ដុំធំៗពីរគឺ ផ្សារដើមគរ និងផ្សារច្បារអំពៅ ។ នៅទីនោះ មានលក់បន្លែ អង្ករ ត្រី សាច់ និងម្ហូបឆ្អិនស្រាប់សាមញ្ញៗ ។ អ្នកលក់ដូរតូចតាចនៅក្នុងផ្សារផលិតផលធំៗទាំងនេះ ភាគច្រើនគឺជាស្ត្រីភេទ ។ ដោយសារអ្នកលក់តូចតាចពុំមានលទ្ធភាពអាចជួលតូបបាន គេដាក់ទំនិញនៅក្នុងកញ្ច្រែង និងអង្គុយលក់តាមកន្លែងផ្សេងៗតាមដែលអាចធ្វើបាន ។ នៅក្នុងផ្សារមួយដែលត្រូវសិក្សា ពួកមន្ត្រីបានប៉ាន់ស្មានថា ស្ត្រីអ្នកលក់ដូរតូចតាចក្រីក្រ មានជាង ៣០០នាក់ ។

## ស្ថានភាពស្ត្រីអ្នកលក់ដូរ

ការសិក្សាក៏បានរកឃើញដែរថា មនុស្សភាគច្រើនបានមកធ្វើជាអ្នកលក់ដូរតូចតាច ដោយសារគេគ្មានច្រកអ្វីផ្សេង ។ ស្ត្រីទាំងនេះដែលគ្មាន ឬមានការ រៀនសូត្រតែបន្តិចបន្តួច មានឱកាសតិចតួចណាស់ ក្នុងការរកការងារផ្សេង ទៀតធ្វើបាន ។ អ្នកខ្លះបានរៀនលក់ដូរពីម្តាយរបស់ខ្លួន ខ្លះទៀតបានតាមអ្នក ជិតខាងមកផ្សារ ឯអ្នកឯទៀត បានចេញលក់ហើយរៀនគិត រៀនចំណាំ បណ្តើរៗតែម្តងទៅ ។

### *ស្ថានភាពធ្វើការងារ*

សំរាម ទឹកលិច កំដៅ និងធូលី គឺជាបញ្ហាធំនៅក្នុងផ្សារជាច្រើន ។ ឯទឹកស្អាតសំរាប់ផឹកក៏ចោទបញ្ហាដូចគ្នា ។ ដោយសារគ្មានទឹកស្អាតផឹក និងគ្មានបង្គន់ ស្ត្រីអ្នកលក់ខ្លះត្រូវអត់ទ្រាំមិនបត់ជើងតូចយូរម៉ោង ដែលអាចធ្វើឱ្យរលាកផ្លោកនោម ឬមានបញ្ហាសុខភាពផ្សេងទៀត ។

### *ពន្ធអាករ និងប្រាក់កំរៃផ្សេងៗ*

ការសិក្សាបានរកឃើញថា គណៈកម្មាធិការផ្សារបានតាក់តែងបទបញ្ជាផ្ទៃក្នុងផ្សារ (ក្នុងនេះមានទាំងរឿង ប្រាក់កំរៃ និងពន្ធអាករប្រចាំថ្ងៃផង) ដែលត្រូវបានដាក់ជូនសាលាក្រុងពិនិត្យ និងផ្តល់ការយល់ព្រម ។ ប៉ុន្តែនៅពេលធ្វើសំភាសន៏ WELR ពីដំបូងៗក្នុងឆ្នាំ១៩៩៧ ពួកអ្នកលក់ដូរបានរាយការណ៏ថា ជួនកាលគាត់មិនដឹងទេថា អ្នកមកទារឱ្យបង់ប្រាក់កំរៃជាអ្នកណា ហើយប្រាក់ដែលត្រូវបង់នោះ ជាប្រាក់អ្វី ។

**តារាង ២. ប្រភពកំចីមុនៗ**

| ប្រភពមូលនិធិ | ភាគរយ |
|---|---|
| អ្នកអោយប្រាក់គេខ្ចី | 81 |
| សាច់ញាតិ ឬមិត្តភក្តិ | 10 |
| អ្នកលក់ឯទៀតក្នុងផ្សារ | 4 |
| កម្មវិធីឥណទានរបស់អង្គការក្រៅរដ្ឋាភិបាល | 4 |
| ផ្សេងៗទៀត | 1 |

*ប្រភព: សំរែកអាជីវករ ឆ្នាំ២០០១*

### *ប្រាក់ចំណូលក្នុងគ្រួសារ*

ដោយសារនៅក្នុងផ្សារវ៉ាអ៊ូអរ មិនអាចនិយាយរឿងលាក់ការណ៍អ្វីកើត ដូច្នេះអ្នកស្រាវជ្រាវមិនបានសួរត្រង់ៗពីកំរិតប្រាក់ចំណូលទេ ។ ប៉ុន្តែគេបានលើកសំនួរថា តើអ្នកមានវិទ្យុ ទូរទស្សន៏ កង់ជិះ ម៉ូតូ រថយន្តឬទេ ។ គេបានរកឃើញថា ធៀបនឹងប្រជាជនមធ្យមក្នុងក្រុងភ្នំពេញ អ្នកលក់ដូរតូចតាចមានទ្រព្យរបស់ទាំងនេះតិចតួចណាស់ ។

ក្នុងចំណោមស្ត្រី ៨៩នាក់ក្នុងអង្កេត WELR មានជាងពាក់កណ្តាលបានប្រាប់ថា ការងាររបស់គាត់ គឺជាប្រភពចំណូលតែមួយគត់ក្នុងគ្រួសារគាត់ ។ មាន ១៨% ទៀតនិយាយថា ខ្លួនគាត់ជាប្រភពចំបងនៃចំនូលគ្រួសារ ។ មានអ្នកលក់ដូរតូចតាចតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានប្តីធ្វើការងារជាអ្នកលីសែង អ្នកធាក់ស៊ីក្លូ ឬកម្មករសំណង់គ្មានជំនាញ ។

### *ផ្ទះសំបែង*

អ្នកសួរសំភាសន៏ WELR បានរកឃើញថា អ្នកលក់ដូរក្រីក្របំផុតជាច្រើននាក់ដែលរកស៊ីនៅផ្សារ ពុំមានផ្ទះរបស់ខ្លួនផ្ទាល់ទេ ។ អ្នកខ្លះជួលផ្ទះគេ អ្នកខ្លះនៅជាមួយបងប្អូន ឯមួយចំនួនតូចគ្មានផ្ទះស្នាក់នៅសោះ ។ ចំពោះអ្នកលក់ដូរតូចតាចដែលមានផ្ទះខ្លួនឯង ផ្ទះនោះជាទូទៅ គឺជាខ្ទមទំហំបីម៉ែត្រក្រឡា ប្រក់ស្លឹក ឬក្រណាត់ផ្លាស្ទិក ។ ផ្ទះតូចៗទាំងនេះច្រើនមានតែមួយបន្ទប់ មានគ្រែឈើមួយគ្មានក្រាលកន្ទេលទេ និងពាងទឹកមួយ ។ ថ្លៃឈ្នួលប្រចាំខែនៃផ្ទះប្រភេទនេះ ប្រែប្រួលពី ១០.០០០ ទៅ ៣០.០០០រៀល ឬលើសពីនេះទៀត ហើយអ្នកឆ្លើយសំភាសន៏និយាយថា ជាញឹកញយ គាត់រកប្រាក់បង់ឱ្យគេមិនបានទេ ។

ទោះបីគេមិនអាចដឹងច្បាស់ថា តើមានស្ត្រីអ្នកលក់ដូរតូចតាចនៅតាមផ្សារប៉ុន្មាននាក់ដែលគ្មានផ្ទះសំបែងសោះក៏ដោយ ក៏អ្នកដែលសំរាកដេកនៅក្នុងផ្សារជាច្រើននាក់បាននិយាយថា គាត់ធ្វើដូច្នេះពីព្រោះគ្មានផ្ទះសោះ ឬផ្ទះគាត់នៅឆ្ងាយពេក ។ ជាក់ស្តែងមានស្ត្រីជាច្រើននាក់បានសំរេចចិត្តទៅលក់ដូរនៅផ្សារមួយចំនួន ពីព្រោះគាត់អាចដេកនៅទីនោះបាន ។ ប៉ុន្តែដេកនៅក្នុងផ្សារ ក៏មានគ្រោះថ្នាក់ច្រើនដែរ ។ ស្ត្រីអ្នកលក់ដូរបានរាយការណ៍ពីគ្រោះថ្នាក់ច្រើនបែបយ៉ាង ដូចជាការវាយដំរូបកាយ ការរំលោភបំពានខាងផ្លូវភេទ និង ការលួចផលិតផល និងទំនិញផ្សេងៗ ។ មួយចំនួនបាននិយាយថា មានការបារម្ភចំពោះកូនចៅ ពិសេសកូនស្រី ដែលអាចត្រូវគេចាប់យកទៅលក់ឱ្យផ្ទះបន ។ អ្នកសំរាកដេកក្នុងផ្សារ ក៏ត្រូវប្រឈមមុខជាប្រចាំនឹងគ្រោះថ្នាក់ត្រូវចាប់ខ្លួន ។ ស្ត្រីទាំងនោះនិយាយថា ទោះបីមុននឹងមកដេកក្នុងផ្សារគាត់បានសុំដល់ពួកមន្ត្រីហើយក៏ដោយ ក៏មានច្រើននាក់ត្រូវបានចាប់ខ្លួនហើយត្រូវបង់ផាកយ៉ាងធ្ងន់ធ្ងរ ដើម្បីបានរួចពីការឃុំឃាំងមកវិញ ។

ស្ត្រីអ្នកលក់ដូរតូចតាច បានរាយការណ៏ថា គាត់ចំណាយពេលលក់ដូរជាមធ្យម ១១ម៉ោង ក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយអាទិត្យ ។ គិតជាមធ្យម ពួកគាត់ក្រោកពីដំណេកនៅម៉ោង ៣.៣០ទៀបភ្លឺ និងត្រូវធ្វើដំណើរ ៤គីឡូម៉ែត្រទៅធ្វើការងារ ។ ជាច្រើននាក់បានប្រាប់ថា គាត់មានការភ័យខ្លាចដោយត្រូវធ្វើដំណើរពីព្រលឹមបែបនេះ ពីព្រោះផ្លូវនៅស្ងាត់ពេក ។ បើគិតទាំងការងារផ្ទះថែមទៅលើការលក់ដូរផង គាត់រាយការណ៏ថា ត្រូវធ្វើការ ១៨ម៉ោង ឬច្រើនជាងនេះទៀតក្នុងមួយថ្ងៃៗ ។

### *ឥណទាន និង បំណុល*

ការសិក្សាបានបង្ហាញថា អ្នកលក់ដូរតូចតាចមានសកម្មភាពច្រើនក្នុងការខ្ចីប្រាក់គេ (ជួនកាលក៏មានឱ្យគេខ្ចីប្រាក់ដែរ) ហើយក៏មានការយល់ដឹងច្បាស់លាស់គួរសមពីផលប្រយោជន៍នៃឥណទានចំពោះរបររកស៊ីរបស់គាត់ ។ ទឹកប្រាក់ខ្ចីប្រែប្រួលពី ១០ដុល្លារ ដល់ ៣៣៣ដុល្លារ (គិតជាមធ្យម ៤៦ ដុល្លារ) ។ រយៈពេលត្រូវបង្វិលសងវិញអាចត្រឹមពីរ-បីថ្ងៃ ទៅដល់ពីរឆ្នាំ ។ ការប្រាក់បង់ឱ្យអ្នកចងការប្រាក់ប្រែប្រួលពី ១០% ដល់ ៤០% ក្នុងមួយខែ ប៉ុន្តែភាគច្រើនស្ថិតក្នុងរង្វង់ ២០% - ៣០% ក្នុងមួយខែ ។ គេអាចឃើញច្បាស់ថា មានអ្នកលក់ដូរតូចតាចតិចនាក់ណាស់ ដែលអាចរកឥណទានមានការប្រាក់សមរម្យបាន ។

### *ការយល់ដឹងពីច្បាប់*

គណៈកម្មាធិការផ្សារបានប្រាប់អ្នកស្រាវជ្រាវ WELR ថា គណៈកម្មាធិការអនុវត្តការងាររបស់ខ្លួនទៅតាមបទបញ្ជា និងបទបញ្ញត្តិជាលាយលក្ខណ៍អក្សរ ។ ប៉ុន្តែអ្នកលក់ដូចតូចតាចដែលបានឆ្លើយសំភាសន៍ក្នុងដំណាក់កាលដំបូងបានរាយការណ៍គ្រប់គ្នាថា គាត់មិនដែលបានឃើញបទបញ្ជា និងបទបញ្ញត្តិទាំងនេះទេ ហើយក៏មិនដែលបានដឹងដោយផ្ទាល់ពីខ្លឹមសាររបស់វាដែរ ។ ស្ថានភាពបែបនេះមិនគ្រាន់តែធ្វើឱ្យអ្នកលក់ដូរតូចតាចងាយរងគ្រោះដោយសារអំពើពុករលួយ និងការរុកគួនរំខានប៉ុណ្ណោះទេ ប៉ុន្តែវាបានបង្កើតឧបសគ្គធំធេងដល់ការកសាងផែនការធ្វើអាជីវកម្មរកចំណេញ ពីព្រោះគេមិនអាចប៉ាន់ស្មានច្បាស់លាស់បានពីបន្ទុកចំណាយ[១] ។

### *សុខភាព និងការថែទាំសុខភាព*

អ្នកលក់ដូរសឹងតែទាំងអស់គ្នាដែលគេបានចុះអង្កេត បានលើកពីបញ្ហាសុខភាពដែលមានសុខភាពរបស់ខ្លួនឯងផ្ទាល់ របស់កូន និងរបស់ប្ដី ។ នៅពេលស្ត្រីអ្នកលក់ដូរតូចតាច ឬសមាជិកគ្រួសារគាត់មានជំងឺ ផលវិបាកវាកើនទ្វេឡើងយ៉ាងឆាប់រហ័ស ហើយផលប៉ះពាល់ខាងសេដ្ឋកិច្ចក៏មានកំរិតធំធេង ។ ដើម្បីរ៉ាប់រងចំណាយថែទាំសុខភាពស្ត្រីជាច្រើនបានប្រាប់ថា គាត់ត្រូវខ្ចីប្រាក់គេ ឬត្រូវលក់អ្វីៗទាំងអស់ដែលអាចរកបាន ។ តាមរបាយការណ៍នេះ ក្រុមអ្នកស្រាវជ្រាវ WELR បានយល់ច្បាស់ថា ដើម្បីមានប្រសិទ្ធិភាព អន្តរាគមន៍នានាដែលសំដៅកែលំអស្ថានភាពសេដ្ឋកិច្ចរបស់អ្នកលក់ដូរតូចតាច ត្រូវតែមានគួបបញ្ចូលយុទ្ធសាស្ត្រមួយ សំរាប់ដោះស្រាយតំរូវការថែទាំសុខភាពជាមូលដ្ឋានរបស់ពួកគាត់ ។

ដោយហេតុថា កម្មវិធី WELR មានគោលដៅដោះស្រាយបញ្ហាធំៗបំផុតដែលស្ត្រីអ្នកលក់ដូរតូចតាចបានលើកឡើង ក្រុមស្រាវជ្រាវបានកសាងឡើងនូវចំណាត់ថ្នាក់មួយនៃចំណុចចូលជាយុទ្ធសាស្ត្រ (strategic entry points) សំរាប់ការធ្វើអន្តរាគមន៍ គឺមានលទ្ធភាពខ្ចីឥណទាន ការបន្ធូរបន្ថយបំណុល ការបណ្ដុះបណ្ដាលអំពីជំនាញធ្វើអាជីវកម្ម ការថែទាំសុខភាព និងការថែទាំកុមារ ។

## ការកសាងកម្មវិធីដើម្បីឆ្លើយតប

**តារាង ៣. មូលហេតុនៃការខ្ចីប្រាក់គេ**

| មូលហេតុ | ភាគរយ |
|---|---|
| សកម្មភាពមុខរបរ | 65.2 |
| វិបត្តិសុខភាព | 15.9 |
| ការទិញអាហារ | 10.1 |
| ការធ្វើចំការ | 2.9 |
| បុណ្យទាន | 1.4 |
| ផ្សេងៗ | 4.3 |
| ភាគរយសរុប | 100 |
| ចំនួនអ្នកឆ្លើយសំភាសន៍ | 69 |

*ប្រភព: សម្ព្រែកអាជីវករ ឆ្នាំ២០០១*

### *ប្រាក់សន្សំ, ឥណទាន, និងការបណ្ដុះបណ្ដាលជាប់ទាក់ទិន*

ក្នុងជំហានដំបូង ក្រុមការងារ WELR បានចាប់ផ្ដើមធ្វើកម្មវិធីប្រាក់សន្សំ និងឥណទានតាមក្រុម ដោយសារហេតុផលបី ។ *ទីមួយ* អ្នកលក់ដូរតូចតាចភាគច្រើនបានកំណត់ថា លទ្ធភាពខ្ចីឥណទានមានការប្រាក់សមរម្យ គឺជាអាទិភាពខ្ពស់បំផុតសំរាប់ពួកគាត់ ។ *ទីពីរ* អ្នកឆ្លើយសំភាសន៍បានប្រាប់ថា ការជំពាក់បំណុលមួយហើយមួយទៀតមិនចេះចប់ គឺជាកត្តាមួយធំដែលសង្កត់ពួកគាត់ឱ្យជាប់ផុងក្នុងស្ថានភាពក្រតោកយ៉ាកបែបនេះ ។ *ទីបី* អ្នកលក់ដូរតូចតាចសឹងតែគ្មានពេល "ទំនេរ" ទេ ។ បើសិនកម្មវិធី WELR មានគោលដៅឱ្យអ្នកលក់ដូរចូលរួមនៅក្នុងយុទ្ធសាស្ត្ររួមមួយ ដើម្បីលើកកំពស់សិទ្ធិអំនាចខាងសេដ្ឋកិច្ច និងខាងផ្លូវច្បាប់របស់ពួកគេ កម្មវិធីនេះត្រូវតែផ្ដល់លទ្ធផលឱ្យបានយ៉ាងឆាប់ ។ លទ្ធផលជាដំបូងៗនៃកម្មវិធីឥណទានបាន បង្ហាញថា វាបានកាត់បន្ថយបន្ទុកបំណុល និងបានបង្កើនសមត្ថភាពរកចំនូលរបស់សមាជិក ។ ក្នុងឆ្នាំ២000 នៅផ្សារទាំងពីរ មានក្រុមប្រាក់សន្សំ និងឥណទានចំនួន ៣៣ក្រុម ដែលមានអ្នកលក់ដូរតូចតាចចូលរួម ៣0២នាក់ ។ ស្ត្រីទាំងនេះបានទទួលឥណទាន ១៥.000.000រៀល និងបានបង្កើតមូលនិធិប្រាក់សន្សំមានទឹកប្រាក់ ៩.២៨៤.000រៀល ដែលផ្ដល់ការប្រាក់បាន ១.៥00.000រៀល ។ គេបានរកឃើញអាំងឌីកាទ័រមួយនៃការប្តេជ្ញាគាំទ្រកម្មវិធីឥណទាន និងប្រាក់សន្សំ ដែលបង្ហាញថា ទោះបីជួបបញ្ហាប្រឈមច្រើនក៏ដោយ ក៏នៅតែមានការសងបំណុលជាបន្តទៀត ។ ក្នុងករណីម្ដងម្កាលដែលមានស្ត្រីណាម្នាក់មិនអាចសងបំណុលទាន់ពេល ក្រុម WELR/USG បានចុះធ្វើការជាមួយកូនបំណុលមានបញ្ហា និងជាមួយក្រុមរបស់គាត់ ដើម្បីកំណត់តារាងពេលសងបំណុលមួយដែលអាចទទួលយកបាន ។ ក្រៅពីកម្មវិធីក្រុមប្រាក់សន្សំ និងឥណទាន បុគ្គលិកគំរោងក៏បានជួយដល់ស្ត្រីមួយចំនួនឱ្យចេះប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។

### *ការបណ្ដុះបណ្ដាលពីអាជីវកម្មតូចៗ*

ការបណ្ដុះបណ្ដាលរបស់ WELR បានជួយបង្រៀនស្ត្រីអ្នកលក់ដូរនូវជំនាញស្នូលនានាដែលចាំបាច់សំរាប់ដំណើរការអាជីវកម្មតូចៗ មានជាអាទិសារៈសំខាន់នៃការកត់ត្រាឱ្យបានច្បាស់លាស់, ម៉ាឃីទិង និងការដាក់តាំងផលិតផល, និងគោលការណ៍ជាមូលដ្ឋានមួយចំនួនខាងសេដ្ឋកិច្ច ដោយផ្ដោតជាពិសេសទៅលើការយកគោលគំនិតទាំងនេះ ទៅអនុវត្តនៅក្នុងស្ថានភាពជាក់ស្ដែងនៃជីវភាពប្រចាំថ្ងៃក្នុងផ្សារ ។

### ***ការជួយរៀបចំ និងការជួយមតិលើបញ្ហាសំខាន់ៗ***

នៅពេលដែលស្ត្រីអ្នកលក់ដូរ មានពិសោធន៍ពីរឿងរចនាសម្ព័ន្ធ និងយន្តការនៃក្រុមប្រាក់សន្សំ និងឥណទានគួរសមហើយ គាត់ក៏ចាប់ផ្តើមប្រើប្រាស់ក្រុមនេះ ដើម្បីដោះស្រាយបញ្ហាដ៏ស្មុគស្មាញខ្លះៗ និងការខាតពេលផ្សេងៗ ដែលគាត់ត្រូវប្រឈមមុខ ។ ដើម្បីបង្កើនសមត្ថភាពពួកគាត់ក្នុងការជួយខ្លួនឯង (នេះជាគោលដៅស្នូលនៃ WELR) កម្មវិធីបានផ្តួចផ្តើមធ្វើសកម្មភាពជាច្រើន ដើម្បីកែលំអចំណេះដឹងរបស់គាត់ពីសិទ្ធិអំណាចរបស់ខ្លួន និងលទ្ធភាពធ្វើការងាររួមគ្នាដើម្បីប្រើប្រាស់សិទ្ធិទាំងនេះ ។

ការជួបប្រជុំនានានៃក្រុមឥណទាន និងការជាប់ពាក់ព័ន្ធជាទៀងទាត់ជាមួយគណៈកម្មាធិការផ្សារ បានផ្តល់នូវលទ្ធផលមួយចំនួន ។ ស្ត្រីអ្នកលក់ដូរតូចតាចបានចាប់ផ្តើមមានចិត្តក្លាហាន ទំនុកចិត្ត និងជំនាញដ៏ចាំបាច់ផ្សេងៗ ដើម្បីលើកឱ្យគេដឹងពីការព្រួយបារម្ភរបស់ខ្លួន ហើយតាមការអនុវត្តន៍ដូច្នេះក៏អាចដោះស្រាយបញ្ហាមួយចំនួនបាន នឹងបានទទួលការចាត់ចែងគ្រប់គ្រងសមរម្យជាងមុនពីសំណាក់មន្ត្រីផ្សារ ។ មួយចំនែកទៀត ស្ត្រីអ្នកលក់ដូរក៏បានពិនិត្យឃើញ និងមានពិសោធបានទទួលអត្ថប្រយោជន៍នៃការធ្វើការងារជាក្រុមដោយផ្ទាល់ ក្នុងនេះមានទាំងកំលាំងធ្វើការចរចា និងទំនាក់ទំនងល្អជាងមុនជាមួយគណៈកម្មាធិការផ្សារ ។

ជាលទ្ធផលនៃការខំប្រឹងប្រែងទាំងនេះ អំពើហិង្សា និងពាក្យសំដីគ្រោតគ្រាតក៏បានថយចុះ ហើយឥឡូវនេះ ស្ត្រីអ្នកលក់ដូរមានលទ្ធភាពបានដឹង បានយល់ពីបទបញ្ជាទាំងឡាយដែលគ្រប់គ្រងផ្សារ ។ ឯការប្រមូលពន្ធ និងប្រាក់កំរៃផ្សេងៗលើការលក់ដូរ នៅមានបញ្ហាខ្លះនៅឡើយ ប៉ុន្តែមានការរីកចំរើន មួយកំរិតដែរ (ភ្នាក់ងារប្រមូលប្រាក់ត្រូវពាក់ផ្លាកសំគាល់ខ្លួន) ។

ពួកសមាជិកកម្មវិធី ក៏បានធ្វើសកម្មភាពបញ្ចុះបញ្ចូលគណៈកម្មាធិការផ្សារឱ្យកែលំអហេដ្ឋារចនាសម្ព័ន្ធក្នុងផ្សារ ។ ក្នុងផ្សារមួយ ស្ត្រីអ្នកលក់ដូរបានរកឃើញថា កង្វះខាតចង្កៀងបំភ្លឺបានធ្វើឱ្យមានបញ្ហាចោទច្រើនខាងសន្តិសុខ ។ ដោយមានការជួយទ្រទ្រង់ពី USG ស្ត្រីអ្នកលក់ដូរដែលភាគច្រើនមិនចេះអក្សរ ក៏បានទទួលជំនួយពីមជ្ឈមណ្ឌលអង្គការសហប្រជាជាតិសំរាប់ការតាំងលំនៅដ្ឋានរបស់មនុស្ស (United Nations Centre for Human Settlements: UNCHS) ដើម្បីដាក់ចង្កៀងបំភ្លឺ ។ ដំណោះស្រាយនេះបានកាត់បន្ថយចំនួនករណីលួចអីវ៉ាន់ និងការរំលោភបំពាន ព្រមទាំងជួយឱ្យអ្នកលក់ដូររកចំណូលបានច្រើនថែមទៀត ពីព្រោះអាចបន្តលក់ដូរដល់យប់បាន ។

### ***ដោះស្រាយបញ្ហាខាងច្បាប់***

ទោះបីយុទ្ធសាស្ត្រជួយទ្រទ្រង់ខាងផ្លូវច្បាប់របស់ WELR កំពុងមានការវិវត្តន៏ក៏ដោយ ក៏ក្រុមការងារ WELR បានជួយទ្រទ្រង់ដល់សមាជិកក្នុងការផ្សះផ្សារជំលោះ និងវិវាទផ្សេងៗ ជាមួយគណៈកម្មាធិការផ្សារ និងអាជ្ញាធរថ្នាក់លើ ។ ក្រុមការងារ WELR ក៏បានជួយដល់អ្នកលក់ដូរជាសមាជិកដែរ នៅពេលមានបណ្តឹងតាមផ្លូវច្បាប់ផ្សេងៗចំពោះពួកគាត់ ។

### ***ការថែទាំកុមារ និង ការថែទាំសុខភាព***

អ្នកលក់ដូរតូចតាច និងបុគ្គលិកកម្មវិធី WELR បានធ្វើការសហការគ្នា ដើម្បីកសាងមជ្ឈមណ្ឌលថែទាំកុមារនៅជិតផ្សារទាំងពីរ និងស្វែងរកមើលសេវាថែទាំសុខភាពដែលមានតំលៃថោក និងមានប្រសិទ្ធិភាព ។ មកទល់ពេលនេះ ជំនួយឧបត្ថម្ភក្នុងវិស័យថែទាំសុខភាព ត្រូវបានធ្វើឡើងតាមករណី ជាក់ស្តែង ដោយសមាជិកក្រុមការងារ WELR ជួយជូនស្ត្រីអ្នកលក់ដូរទៅ កាន់គ្លីនិកថែទាំសុខភាពដែលមានតំលៃថោក និងដែលតាមធម្មតា អ្នកលក់ដូរតូចតាចទាំងនោះ មិនបានដឹង ឬពុំមានលទ្ធភាពទៅព្យាបាលខ្លួនទេ ។

### ***ការកសាងសមត្ថភាពដឹកនាំរបស់ពួកសមាជិក***

សមាសភាគដ៏សំខាន់មួយនៃកម្មវិធី WELR គឺកសាងសមត្ថភាពរបស់អ្នកលក់ដូរជាសមាជិកក្នុងជំនាញដឹកនាំ និងគ្រប់គ្រងជាលក្ខណៈប្រជាធិបតេយ្យ ។ ទាំងនេះសុទ្ធសឹងជាជំនាញដែលនឹងជំរុញសមាជិកកម្មវិធី WELR ឱ្យរីកចំរើនហួសឆ្ងាយពីគំនិតដើមនៃកម្មវិធី WELR ហើយវាក៏នឹងមានផលប៉ះពាល់ជាវិជ្ជមាន លើគ្រប់រូបភាពនៃជីវភាពរបស់ស្ត្រីអ្នកលក់ដូរ ។

---

...តពីទំព័រទី ៥

## ឧស្សាហកម្មកាត់ដេរ...

***ការចូលជាសមាជិកក្នុង WTO*** មានសារៈសំខាន់ជាគន្លឹះដើម្បីឱ្យកម្ពុជាអាចប្រកួតប្រជែងបានជាបន្តទៀត ជាមួយប្រទេសផ្សេងៗ ។ ប៉ុន្តែដើម្បីបានចូលជាសមាជិក WTO ប្រទេសកម្ពុជាត្រូវបំពេញលក្ខខណ្ឌមួយចំនួនដែលមានជាអាទិ ការកែលំអ និងការដាក់អនុវត្តន៏ច្បាប់ពាណិជ្ជកម្ម, និងការរក្សាឱ្យមានប្រព័ន្ធតុលាការមួយដែលយុត្តិធម៌ និងមានប្រសិទ្ធភាព ។

***ការកាត់បន្ថយបន្ទុកចំណាយលើទឹកភ្លើង និងដីធ្លី និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ*** អាចជួយរក្សាសមត្ថភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរកម្ពុជា ។ ការងារនេះមានជាអាទិ ការកាត់បន្ថយអត្រាពន្ធដ៏ខ្ពស់លើថាមពល ដើម្បីឱ្យវាចុះថ្លៃមកនៅប្រហាក់ប្រហែលជាមួយប្រទេសជិតខាង ការកែលំអផ្លូវ និងរូបភាពផ្សេងទៀតនៃប្រព័ន្ធដឹកជញ្ជូន, និងការផ្តល់ឱ្យអ្នកវិនិយោគខាងឧស្សាហកម្មនូវសុវត្ថិភាពនៃកម្មសិទ្ធលើដីធ្លីដែលគេទិញ ។ ការពង្រីកទីផ្សារនាំចេញ ដើម្បីចូលទៅក្នុងប្រទេសជប៉ុន, អូស្ត្រាលី, និង ប្រទេសអាស៊ីឯទៀតៗ ក៏សំខាន់ណាស់ដែរ ពីព្រោះតំបន់អាស៊ី-ប៉ាស៊ីហ្វិក មានប្រជាជនរស់នៅដល់ទៅ ៥០០លាននាក់ ។

### ឯកសារយោង

Ministry of Commerce (2000), Cambodia Opportunity for the New Millennium: Business and Investment Handbook 2000, (Phnom Penh: Ministry of Commerce)

Us Embassy (2000) Labour Trends Report: Cambodia August 2000, Economic/Commercial Section of the US Embassy to Phnom Penh, Cambodia.

Mclean, Alexandra (1999), "Sewing a Better Future?" (Phnom Penh: CARE International).

# តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស

ទិន្នន័យថ្មីៗបានបង្ហាញថា សេដ្ឋកិច្ចនៅក្នុងពិភពលោកបានធ្លាក់ល្បឿនកំណើនជាទូទៅ ។ ដើម្បីជំរុញសេដ្ឋកិច្ច អត្រាការប្រាក់ត្រូវបានកាត់បន្ថយ ប៉ុន្តែវិធានការនេះហាក់ដូចជាមិនសក្តិសិទ្ធទេ ហើយសេដ្ឋកិច្ចនៃប្រទេសអាស៊ីនានា ក៏ចាប់ផ្តើមទទួលរងការប៉ះទង្គិចហើយ ។ ក្នុងប្រទេសខ្លះ ការលំបាកខាងសេដ្ឋកិច្ចហាក់ដូចបានបង្កើនការរំជើបរំជួលខាងសង្គមកិច្ច និងនយោបាយកាន់តែធ្ងន់ធ្ងរឡើង ។ ចំពោះសេដ្ឋកិច្ចសហរដ្ឋអាមេរិកវិញ ទោះបីវាបានចុះខ្សោយក៏ដោយ ក៏ប្រាក់ដុល្លារនៅតែរឹងប៉ឹងធៀបនឹងរូបិយវត្ថុចំបងៗផ្សេងទៀត ឯអត្រាអតិផរណាក៏គ្មានការប្រែប្រួលគួរឱ្យកត់សំគាល់ដែរ ។

## កំណើនសេដ្ឋកិច្ចក្នុងពិភពលោក

ទិន្នន័យសេដ្ឋកិច្ចដែលទើបផ្សព្វផ្សាយថ្មីៗ បានបង្ហាញយ៉ាងច្បាស់ថា សេដ្ឋកិច្ចក្នុងពិភពលោកកំពុងថយល្បឿនលូតលាស់ ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើនតែ ២.៥% ប៉ុណ្ណោះនៅក្នុងត្រីមាសទី១ ឆ្នាំ២០០១, ធៀបនឹងកំណើន ៣,៥% នៅក្នុងត្រីមាសទី៤ និង ៥,៣% ក្នុងត្រីមាសទី៣ ឆ្នាំ២០០០ ។ កំណើនសេដ្ឋកិច្ចក្នុងបណ្តាប្រទេសប្រើប្រាក់អឺរ៉ូ បានថយចុះប្រហែល ១% នៅក្នុងត្រីមាសទី១ ឆ្នាំ២០០១ បើធៀបទៅនឹងត្រីមាសមុន ។ នៅជប៉ុន កំណើន ផសស (GDP) បានស្ទុះឡើងវិញក្នុងត្រីមាសទី៤ ឆ្នាំ២០០០ ប៉ុន្តែទិន្នន័យថ្មីៗបានបង្ហាញថា ផលិតកម្មឧស្សាហកម្ម ជប៉ុនបានថយចុះ ៤% ក្នុងរយៈពេលមួយឆ្នាំមុនខែមេសា ឆ្នាំ២០០១ ឯអត្រាអត់ការងារធ្វើនៅជប៉ុនបានឡើងដល់ ៤,៩% (ជិតដល់កំរិតកំពូល) ។

ដើម្បីទប់ស្កាត់ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងប្រទេសខ្លួន រដ្ឋាភិបាលអាមេរិក, អឺរ៉ុប និងជប៉ុន បានបន្ថយអត្រាការប្រាក់ និងធ្វើការកែតំរូវខាងហិរញ្ញវត្ថុផ្សេងៗ ដើម្បីបន្ធូរឥណទាន ។ ប៉ុន្តែមកទល់សព្វថ្ងៃ វិធានការទាំងនេះមិនសូវមានផលប៉ះពាល់ជាវិជ្ជមានទេ ។ អង្កេតមួយធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០០១ ដោយទស្សនាវដ្តីអង់គ្លេស The Economist បានបង្ហាញថា ការលូតលាស់សេដ្ឋកិច្ចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវចុះខ្សោយក្នុងឆ្នាំ២០០១ ប៉ុន្តែនឹងរើបឡើងវិញនៅឆ្នាំ២០០២ ។ លទ្ធផលអង្កេតបង្ហាញថា កំនើនសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកមានតែ ១,៥% ប៉ុណ្ណោះ ក្នុងឆ្នាំ២០០១ ប៉ុន្តែនឹងឡើងដល់ ៣% ក្នុងឆ្នាំ២០០២ (ធៀបនឹង ៥% ក្នុងឆ្នាំ២០០០) ។ សំរាប់ប្រទេសប្រើប្រាក់អឺរ៉ូអង្កេតរបស់ The Economist បានព្យាករណ៍កំណើនសេដ្ឋកិច្ច ២,៣% ក្នុងឆ្នាំ២០០១ និង ២,៦% ក្នុងឆ្នាំ២០០២ (ធៀបនឹង ៣,៣% ក្នុងឆ្នាំ២០០០) ។ សំរាប់ជប៉ុន គេរំពឹងថា មានកំនើនសេដ្ឋកិច្ច ០,៦% ក្នុងឆ្នាំ២០០១ និង ១,៣% ក្នុងឆ្នាំ២០០២ (ធៀបនឹង ១,២% ក្នុងឆ្នាំ២០០០) ។

នៅទ្វីបអាស៊ីក្នុងពេលនេះ ការធ្លាក់ល្បឿនសេដ្ឋកិច្ចអាចពិនិត្យឃើញសឹងតែគ្រប់ទិសទី លើកលែងតែនៅប្រទេសចិន ដែលមានកំណើនសេដ្ឋកិច្ចកំរិតខ្ពស់ដដែលគឺ ៨,១% ក្នុងត្រីមាសទី១ ឆ្នាំ២០០១ ។ ប៉ុន្តែនៅហុងកុង កំណើន ផសស បានធ្លាក់ដល់ ២,៥% ក្នុងត្រីមាសទី១ ឆ្នាំ២០០១ គឺចុះពី ៧,៣% កាលពីត្រីមាសមុន ។ នៅកូរ៉េខាងត្បូង កំណើន ផសស នៅតែបន្តធ្លាក់ចុះទៀតក្នុងត្រីមាសទី១ ឆ្នាំ២០០១ (បានតែ ៣,៧% ប៉ុណ្ណោះ) បន្ទាប់ពីការធ្លាក់ចុះយ៉ាងគំហុក ក្នុងត្រីមាសមុន ។ ក្នុងបណ្តាប្រទេសអាស៊ានសភាពការណ៍សេដ្ឋកិច្ចក៏មិនសូវល្អដូចគ្នា ។ ក្នុងត្រីមាសទី១ ឆ្នាំ២០០១ សិង្ហបុរីបានជួបការធ្លាក់ចុះពិតមួយនៃសកម្មភាពសេដ្ឋកិច្ច ដោយមានអត្រាកំណើន ផសស តែ ៤,៥% ប៉ុណ្ណោះ ដែលជាការធ្លាក់ចុះគួរឱ្យកត់សំគាល់មួយពីអត្រា ១០% ក្នុងត្រីមាសមុន ។ ឯប្រទេស ថៃ, ម៉ាឡេស៊ី, ហ្វីលីពីន, និងឥណ្ឌូណេស៊ី, ក៏មាននិន្នាការធ្លាក់ចុះប្រហែលគ្នានេះដែរ ។

ការគួបផ្សំរវាងភាពក្រីក្រយ៉ាងធ្ងន់ធ្ងរក្នុងតំបន់ជនបទ និងការធ្លាក់ល្បឿនសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ន បានធ្វើឱ្យស្ថានការណ៍នយោបាយផ្ទុះវឹកវរនៅក្នុងប្រទេសអាស៊ីមួយចំនួន ។ ជាឧទាហរណ៍ យោងតាមទស្សនាវដ្តី Far Eastern Economic Review (May 24, 2001) នៅហ្វីលីពីន ការចាប់ខ្លួនអតីតប្រធានាធិបតី Joseph Estrada សឹងតែបានធ្វើឱ្យមានរដ្ឋប្រហារកើតឡើង ។ ក្នុងប្រជាជនច្រើន ម៉ឺននាក់ដែលធ្វើបាតុកម្មក្នុងក្រុងម៉ានីល មនាច្រើននាក់ណាស់ជាអ្នកជនបទ ដែលបានមករស់នៅក្នុងទីក្រុង ដើម្បីគេចខ្លួនពីជីវភាពក្រខ្សត់ ។ ដើម្បីទប់ស្កាត់កុំឱ្យមានការបះបោរទៀត រដ្ឋាភិបាលហ្វីលីពីន បានផ្តល់ត្រី និងអង្ករ ឱ្យប្រជាជន និងបានសន្យាបង្កើនចំណាយនៅក្នុងតំបន់ជនបទ ដែលជាចំណែកមួយនៃសង្គ្រាមប្រឆាំងនឹងភាពក្រីក្រ ។ ប៉ុន្តែគួរឱ្យស្តាយដោយកន្លងមក រដ្ឋាភិបាលបានសន្យាបែបនេះដែរ ប៉ុន្តែលទ្ធផលឃើញមានតិចតួចណាស់ ។ តាមមតិធនាគារពិភពលោក ក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៩៥ ចំនួនប្រជាជនហ្វីលីពីនដែលរស់នៅក្នុងភាពក្រីក្របានកើនពី ១៥លាននាក់ ដល់ជាង ១៧លាននាក់ ។ ក្នុងពេលបច្ចុប្បន្ននេះជាងមួយភាគបីនៃប្រជាជនហ្វីលីពីន មានចំណូលទាបជាង ១ដុល្លារក្នុងមួយថ្ងៃ ហើយភាគច្រើនរស់នៅតាមជនបទ ។ ជារៀងរាល់ថ្ងៃ មានប្រជាជនច្រើននាក់ បានធ្វើចំណាកស្រុកមកក្រុងម៉ានីល ដើម្បីរកការងារធ្វើ ។ ប៉ុន្តែដោយការងារមិនសូវមាន ជនចំណាកស្រុកជាច្រើននាក់ បានធ្លាក់ខ្លួនជាអ្នកកកាយគំនរសំរាម ដើម្បីរើសរបស់អេតចាយលក់វិញ ។ ការរើសអេតចាយពីសំរាមនេះ ថ្វីបើវាកខ្វក់ និងគ្រោះថ្នាក់ក៏ដោយ ក៏បានចំណូលច្រើនជាងការងារកសិដ្ឋានដែរ ។

## អតិផរណានៅក្នុងពិភពលោក

នៅក្នុងត្រីមាសទី១ ឆ្នាំ២០០១ អត្រាអតិផរណានៅសហរដ្ឋអាមេរិក អឺរ៉ុប និងជប៉ុន មានការប្រែប្រួលតិចតួចណាស់ ។ សភាពការណ៍ ក៏ដូចគ្នាដែរនៅក្នុងប្រទេសអាស៊ីលើកលែងតែកូរ៉េខាងត្បូង ហ្វីលីពីន និងឥណ្ឌូនេស៊ីចេញ ដែលនៅទីនោះថ្លៃទំនិញនាំចូលបានកើនឡើងគួរឱ្យកត់សំគាល់ ដោយសារការធ្លាក់ថ្លៃរូបិយវត្ថុ ។ ឧទា. នៅកូរ៉េខាងត្បូង អតិផរណាមានកំរិត ៤,៣% ក្នុងត្រីមាសទី១ ឆ្នាំ២០០១ គឺកើនពី ២,៩% ក្នុងត្រីមាសមុន ។ ក្នុងរយៈពេលដូចគ្នា អតិផរណានៅឥណ្ឌូណេស៊ីកើនពី ៨,៦% ដល់ ១០,៥% ។

## អត្រាប្តូរប្រាក់នៅក្នុងទីផ្សារពិភពលោក

ពត៌មានថ្មីៗបង្ហាញថា ដុល្លារអាមេរិក ស្ថិតនៅរឹងប៉ឹងដដែល ធៀបនឹង ប្រាក់អឺរ៉ូ និងរូបិយវត្ថុប្រទេសអាស៊ីនានា ។ សភាពការណ៍នេះប្រហែលកើតឡើងដោយសារឈ្មួញរូបិយវត្ថុរំពឹងថា កំណើនសេដ្ឋកិច្ចនៅអឺរ៉ុប និងអាស៊ីនឹងធ្លាក់ចុះខ្លាំងជាងនៅសហរដ្ឋអាមេរិក ។ នៅដើមខែមិថុនាឆ្នាំ២០០១ មួយដុល្លារអាមេរិកប្តូរបាន ១,១៥អឺរ៉ូ ឬ ១២០យ៉េន គឺឡើងថ្លៃពី ១,០៧អឺរ៉ូ និង ១១៥យ៉េន នៅដើមខែមករា ។ នៅក្នុងរយៈពេលជាមួយគ្នា ដុល្លារអាមេរិកក៏បានឡើងថ្លៃគួរឱ្យសំគាល់ដែរ បើធៀបនឹងរូបិយវត្ថុអាស៊ីឯទៀតៗ ឧទា.

## តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស

នៅដើមខែមិថុនា មួយដុល្លារប្តូរបាន ៤៦បាតថៃ ឬ ១១.៤០០រូពីយ៉ាឥណ្ឌូណេស៊ី ។ កាលពីដើមឆ្នាំនេះ វាប្តូរបាន ៤៣បាត ឬ ៩.៥០០រូពីយ៉ា ។

### ថ្លៃផលិតផលនៅក្នុងទីផ្សារពិភពលោក

ការធ្លាក់ល្បឿនសេដ្ឋកិច្ចជាសាកល នៅតែបន្តគាបសង្កត់ថ្លៃផលិតផលនានានៅក្នុងទីផ្សារពិភពលោក ។ អង្ករលេខ១ នៅបាងកកបានធ្លាក់ថ្លៃបន្តទៀត គឺលក់បាន ១៨២ដុល្លារក្នុងមួយតោននៅត្រីមាសទី១ ឆ្នាំ២០០១ ធៀបនឹង ១៨៥ដុល្លារក្នុងមួយតោនកាលពីត្រីមាសមុន ។ សំណើ្តកស្បៀងកៅស៊ូ និងឈើ ក៏ដើរតាមនិន្នាការនេះដែរ ។ ថ្លៃប្រេងឆៅនៅ Dubai បានធ្លាក់ចុះដែរ គឺលក់បាន ២៤ដុល្លារក្នុងមួយធុងក្នុងត្រីមាសទី១ ឆ្នាំ២០០១ ធៀបនឹង ២៨ដុល្លារក្នុងមួយធុងកាលពីត្រីមាសមុន ។

*រៀបចំឡើងដោយលោក សុក ហាច*

**តារាង១. កំនើន GDP ពិតនៃដៃគូពាណិជ្ជកម្មជ្រើសរើស ចាប់ពីឆ្នាំ១៩៩៩ ដល់ ២០០១ (កំណើនភាគរយធៀបនឹងឆ្នាំមុន)**

| | 1999 | | | 2000 | | | | 2001 | 1999 | 2000 |
|---|---|---|---|---|---|---|---|---|---|---|
| | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | - | - | - | - | - | - | - | - | 4.5 | 4.0 |
| ឥណ្ឌូនេស៊ី | 2.0 | 0.5 | 5.8 | 3.2 | 4.1 | | 5.2 | 4.0 | -0.5 | 4.4 |
| ម៉ាឡេស៊ី | 4.1 | 8.2 | 10.6 | 11.7 | | | 6.5 | 3.2 | 5.4 | 8.7 |
| សិង្ហបុរី | 6.7 | 8.2 | 7.1 | 9.1 | 8.0 | | 10.5 | 4.5 | 5.7 | 9.5 |
| ថៃ | 3.5 | 7.7 | 6.5 | 5.2 | | | 3.1 | - | 4.7 | |
| វៀតណាម | - | - | - | - | - | - | - | - | 4.8 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| ចិន | 7.1 | 7.0 | 6.8 | 8.1 | 8.3 | 8.2 | 7.3 | 8.1 | 7.3 | 8.0 |
| ហុងកុង | 1.1 | 4.4 | 8.7 | 14.3 | | 10.4 | 6.8 | 2.5 | 2.9 | 10.6 |
| កូរ៉េខាងត្បូង | 9.9 | 13.4 | 13.0 | 12.8 | | 9.2 | 9.2 | 3.7 | 10.7 | 10.1 |
| តៃវ៉ាន់ | 6.5 | 5.1 | 6.8 | 7.9 | | 6.6 | 4.1 | 1.1 | 5.3 | 6.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| Euro-11 | 1.7 | 2.2 | 3.1 | 3.4 | | 3.0 | 3.0 | - | 2.1 | 3.3 |
| ជប៉ុន | 0.9 | 1.0 | 0.0 | 0.8 | | | 2.8 | - | 0.5 | 1.2 |
| សហរដ្ឋអាមេរិក | 3.8 | 4.3 | 4.6 | 5.0 | 6.0 | | 3.4 | 2.7 | 4.1 | 5.0 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ ។*

**តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ចាប់ពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០១ (កំណើនភាគរយធៀបនឹងឆ្នាំមុន)**

| | 1999 | | | 2000 | | | | 2001 | 1999 | 2000 |
|---|---|---|---|---|---|---|---|---|---|---|
| | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.4 | 1.8 | 0.0 | 0.2 | -2.3 | - | 0.5 | -0.8 | 4.0 | -0.7 |
| ឥណ្ឌូនេស៊ី | 30.9 | 6.6 | 1.7 | -0.6 | 1.1 | | - | - | 20.5 | |
| ម៉ាឡេស៊ី | 2.7 | 2.3 | 2.1 | 1.5 | 1.4 | | 1.7 | 1.5 | 2.7 | 1.5 |
| សិង្ហបុរី | 0.1 | 0.9 | 1.5 | -1.5 | 0.8 | | 2.0 | 1.7 | 0.5 | 0.7 |
| ថៃ | -0.4 | -1.0 | 0.1 | 0.8 | 1.6 | 2.2 | 1.6 | 1.8 | 0.4 | 1.6 |
| វៀតណាម | - | - | - | - | - | - | - | - | 4.0 | |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | -2.1 | -1.3 | -0.8 | 0.1 | 0.1 | | 0.6 | 1.3 | -1.4 | 0.3 |
| ហុងកុង | -4.0 | -5.9 | -4.1 | -5.2 | -4.4 | - | -2.0 | -1.8 | -4.0 | -3.6 |
| កូរ៉េខាងត្បូង | 0.6 | 0.7 | 1.3 | 1.5 | 1.4 | | 2.9 | 4.3 | 0.8 | 2.3 |
| តៃវ៉ាន់ | -0.8 | 0.6 | 0.1 | 1.1 | 1.4 | | - | - | 0.4 | |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| Euro-11 | 1.0 | 1.1 | 1.5 | 2.0 | 2.1 | | 2.7 | 2.5 | 1.1 | 2.3 |
| ជប៉ុន | -0.3 | 0.0 | -1.0 | -0.7 | -0.7 | - | -0.6 | -0.1 | -0.3 | -0.7 |
| សហរដ្ឋអាមេរិក | 2.1 | 2.3 | 2.6 | 3.2 | 3.2 | | 3.4 | 3.4 | 2.2 | 3.3 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ ។*

# តារាងសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស

## តារាង៣. អត្រាប្តូរប្រាក់ក្នុងស្រុកធៀបនឹងដុល្លារ របស់ដៃគូពាណិជ្ជកម្មជ្រើសរើស ចាប់ពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០១ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1999 | | | 2000 | | | | 2001 | 1999 | 2000 |
|---|---|---|---|---|---|---|---|---|---|---|
| | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3,822 | 3,885 | 3,808 | 3,822 | 3,845 | 3,912 | 3,906 | 3,925 | 3832 | 3,871 |
| ឥណ្ឌូនេស៊ី ( រូពីយ៉ា) | 7,921 | 7,531 | 7,193 | 7,340 | 8,279 | 8,693 | 9,297 | 9,780 | 7,855 | 8,402 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.8 | 3.80 | 3.8 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.71 | 1.69 | 1.67 | 1.71 | 1.72 | 1.73 | 1.74 | 1.75 | 1.69 | 1.72 |
| ថៃ ( បាត) | 37.2 | 38.3 | 38.8 | 37.8 | 38.6 | 40.9 | 43.3 | 43.2 | 37.8 | 40.2 |
| វៀតណាម ( ដុង) | 13,931 | 13,960 | 14,009 | 14,060 | 14,060 | 14,150 | | 14,556 | 13,950 | 14,163 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ុន) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 |
| ហុងកុង ( ដុល្លារហុងកុង) | 7.75 | 7.76 | 7.77 | 7.78 | 7.79 | 7.79 | 7.80 | 7.80 | 7.76 | 7.79 |
| កូរ៉េខាងត្បូង (WON) | 1,190 | 1,195 | 1,173 | 1,125 | 1,116 | 1,115 | 1,167 | 1,272 | 1,189 | 1,131 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$) | 33.4 | 32.2 | 32.0 | 30.8 | 31.7 | 32.8 | 32.1 | 32.4 | 31.6 | 31.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| Euro-11 (euro) | 0.95 | 0.95 | 0.96 | 1.03 | 1.07 | 1.10 | 1.15 | 1.08 | 0.94 | 1.09 |
| ជប៉ុន ( យ៉េន) | 131 | 114 | 106 | 109 | 107 | 108 | 110 | 118 | 118 | 109 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ ។*

## តារាង៤. ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក ចាប់ពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០០ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1999 | | | 2000 | | | | 2001 | 1999 | 2000 |
|---|---|---|---|---|---|---|---|---|---|---|
| | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q1-Q4 | Q1-Q4 |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី($/ម៣) | 178 | 196 | 199 | 189 | 193 | 192 | 186 | 171 | 187 | 190 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 585 | 632 | 643 | 641 | 633 | 593 | 530 | 507 | 601 | 599 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 596 | 573 | 689 | 700 | 714 | 684 | 669 | 632 | 634 | 692 |
| អង្ករ - បាងកក ($/តោន) | 245 | 247 | 225 | 240 | 205 | 185 | 185 | 182 | 249 | 204 |
| សណ្តែកសៀង - សហរដ្ឋ ($/តោន) | 200 | 196 | 200 | 212 | 224 | 201 | 209 | 202 | 200 | 212 |
| ប្រេងកាតឆៅ Dubai ($/ធុង) | 15 | 20 | 23 | 24 | 25 | 28 | 28 | 24 | 17 | 26 |
| មាស - LONDON ($/fine ounce) | 274 | 259 | 296 | 290 | 284 | 277 | 267 | 264 | 279 | 280 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ ។*

...តពីទំព័រទី២៤

# ព័ត៌មានថ្មីៗពី...

## ផ្នែកបោះពុម្ពផ្សាយ

នៅខែមេសា ផ្នែកនេះបានបោះពុម្ពផ្សាយខិតប័ណ្ណព័ត៌មានស្តីពី វបសអ និង CPD ផ្សេងពីគ្នា ។ សៀវភៅរបស់ វបសអ សំរាប់គំរោង DAN ស្តីពីទីផ្សារពលកម្មនៅក្នុងសេដ្ឋកិច្ចទីផ្សារអន្តរកាលនៅអាស៊ីអគ្នេយ៍ និងប្រទេសថៃក៏បានបោះផ្សាយនៅខែមេសាផងដែរ ។ និទានុប្បវដ្តប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា និងរបាយការណ៍ប្រចាំឆ្នាំ ក៏បានចាប់ផ្តើមរៀបរៀងនៅខែឧសភាកន្លងមក ។ ឯកសារដែលនឹងចេញផ្សាយឆាប់ៗនេះ រួមមានទីផ្សារពលកម្មនៅកម្ពុជា (ឯកសារពិភាក្សាលេខ ១៨) ការវាយតំលៃបញ្ហាសេដ្ឋកិច្ចសង្គមដែល វបសអ ស្រាវជ្រាវរួមជាមួយ NIAS ( ឯកសារពិភាក្សាលេខ ១៩) និងគំហើញពីការស្រាវជ្រាវពីររបស់ CPD (ស្តីពីបេសកកម្មស្វែងរកការពិតទៅតំបន់អតីតខ្មែរក្រហម និងយុទ្ធវិធីដោះស្រាយទំនាស់ ) ។

# តាមដានសេដ្ឋកិច្ច_សកម្មភាពក្នុងប្រទេស

ការលូតលាស់ខ្លាំងក្នុងវិស័យនាំចេញសំលៀកបំពាក់, ទេសចរណ៍ និងទូរគមនាគមន៍ត្រូវបានរំពឹងថា នឹងរួមចំណែកក្នុងកិរតគួរឱ្យកត់សំគាល់ដល់ការរីកចំរើនសេដ្ឋកិច្ចក្នុងត្រីមាសទី១ ឆ្នាំ២០០១ ។ ប៉ុន្តែចំពោះសកម្មភាពសំណង់ឯកជន និងវិនិយោគផ្ទាល់ពីបរទេសវិញ វាបានថយចុះនៅក្នុងត្រីមាសនេះ ។ កាលពីដើមឆ្នាំ ២០០១ មានការពិនិត្យកែប្រែច្បាប់វិនិយោគទុនរបស់កម្ពុជា ប៉ុន្តែដូចជាពុំឃើញមានផលប៉ះពាល់អ្វីគួរឱ្យកត់សំគាល់ទេ ចំពោះ សេដ្ឋកិច្ច ។ ចលនារូបិយវត្ថុនៅក្នុងត្រីមាសទី១ មានលំនឹងល្អ ។ សំរាប់ត្រីមាសនេះ តាមប្រភពពត៌មានពីវិជ្ជាស្ថានជាតិស្ថិតិ អត្រាអតិផរណានៅភ្នំ ពេញគឺ-០,៨% (ចុះពី ០,១% កាលពីត្រីមាសទី១ ឆ្នាំ២០០០) ។ អត្រាប្តូរ ប្រាក់គឺ ៣.៩២៥រៀលក្នុងមួយដុល្លារអាមេរិក ។ ដោយសារសេដ្ឋកិច្ចកម្ពុជា ប្រើប្រាស់ដុល្លារ ប្រាក់រៀលកម្ពុជាមានតំលៃខ្លាំង ធៀបនឹងប្រាក់បាតថៃ និងដុងវៀតណាម ។ ម្យ៉ាងវិញទៀត ការធ្វើឯកជនភាវូបនីយកម្មនៃធនាគារពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា និងការអនុវត្តន៍ច្បាប់ធនាគារថ្មី គឺជាជំហានចំបងពីរនៅក្នុងដំណើរការកែទំរង់វិស័យធនាគារ ។

## សកម្មភាពសេដ្ឋកិច្ច

វិស័យកសិកម្ម ហាក់ដូចជារើបឡើងវិញបានល្អគ្រាន់បើ ទោះបីជាមានគ្រោះទឹកជំនន់បំផ្លិចបំផ្លាញនៅខែវស្សាកាលពីឆ្នាំមុនក៏ដោយ ។ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានប៉ាន់ស្មានថា ផលស្រូវវស្សាឆ្នាំ២០០០ មានប្រមាណ ៣,២លានតោន (ប្រៀបនឹង ៣,៣តោន កាលពីឆ្នាំមុន) ។ ផលស្រូវនេះគួបនឹងស្តុកស្រូវអង្ករដែលមានស្រាប់ នឹងធ្វើអោយប្រទេសកម្ពុជាមានស្រូវអង្ករគ្រប់គ្រាន់សំរាប់ឆ្នាំនេះ ។ ប៉ុន្តែក្នុងវិស័យកសិកម្ម វាមិនមែនល្អគ្រប់រឿងនោះទេ ។ ការធ្លាក់ថ្លៃអង្ករនៅទីផ្សារបាងកក និងការចុះថ្លៃកៅស៊ូនៅកូឡាឡាំពួរ បានប៉ះពាល់យ៉ាងខ្លាំងដល់កសិករ និងអ្នកដាំកៅស៊ូកម្ពុជា ។ ក្នុងស្ថានភាពបែបនេះ ការបង្កើនចំនួនមុខដំណាំដាំដុះប្រហែលជាវិធីដ៏ល្អមួយដើម្បីជួយរក្សា ស្ថិរភាពប្រាក់ចំណូលរបស់កសិករ ឧទាហរណ៍កសិករមួយចំនួននៅខេត្តស្វាយរៀង បានចាប់ផ្តើមដាំអំពៅសំរាប់នាំចេញ ទៅប្រទេសវៀតណាមហើយ ។

ឧស្សាហកម្មកាត់ដេរបានរីកលូតលាស់បន្តទៀត និងបានគ្របដណ្តប់លើការនាំចេញរបស់កម្ពុជា ។ តួលេខរបស់ក្រសួងពាណិជ្ជកម្មបង្ហាញថា ការនាំចេញទៅសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកបានបន្តកើនឡើង ។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០០១ សំលៀកបំពាក់នាំចេញមានតំលៃសរុប ២៥២លានដុល្លារ គឺបានកើន ២៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ នៅឆ្នាំ២០០០ ផលិតផលសំលៀកបំពាក់កម្ពុជាស្ទើរតែទាំងអស់ (ប្រហែល ៩០%) សំរាប់បំរើការនាំចេញ ហើយមានតែប្រហែល ១០% ប៉ុណ្ណោះដែលត្រូវបានលក់ក្នុង ស្រុក (ប្រហែល ៣៣% នៃសំលៀកបំពាក់លក់ ក្នុងស្រុកត្រូវបាននាំចូល) ។ ការបង្កើនកូតានាំចេញទៅសហរដ្ឋអាមេរិក គឺជាចំណុចគន្លឹះសំរាប់ទ្រទ្រង់ ឧស្សាហកម្មកាត់ដេរកម្ពុជា ហើយដើម្បីសំរេចគោលដៅនេះ ត្រូវមានការជឿនលឿនថែមទៀតលើការអនុវត្តស្តង់ដារការងារ ។ ក្នុងវិស័យកាត់ដេរនៅប៉ុន្មានខែខាងមុខនេះ គេអាចជួបការលំបាកមួយចំនួនដែលជាប់ទាក់ទិននឹងកំលាំងពលកម្ម គឺនៅពេលដែលសហជីពកម្មករជំរុញអោយមានការកាត់បន្ថយម៉ោងធ្វើការក្នុងមួយអាទិត្យពី ៤៨ម៉ោង មក ៤៤ម៉ោង ។

វិស័យទេសចរណ៍ដែលជាវិស័យមានចំណូលរូបិយប័ណ្ណធំបំផុតទីពីររបស់កម្ពុជា បានបន្តរីកលូតលាស់យ៉ាងទៀងទាត់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ទោះបីមានការប្រែប្រួលតាមរដូវកាលខ្លះៗក៏ដោយ ។ ការមកដល់របស់ភ្ញៀវទេសចរតាមព្រលានយន្តហោះសៀមរាប មានសន្ទុះកំនើនលឿនជាងការមកដល់របស់ភ្ញៀវតាមព្រលានយន្តហោះពោចិនតុងភ្នំពេញ ។ នៅត្រីមាសទី១ ឆ្នាំ២០០១ ចំនួនភ្ញៀវទេសចរចូលមានសរុប ១៣០.២៤៧នាក់ គឺបានកើន ២៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០០ ។ នយោបាយបើកចំហជើងមេឃដែលអនុវត្តនៅចុងឆ្នាំ១៩៩៧ និងដែលអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរបរទេសធ្វើការហោះហើរផ្ទាល់មកខេត្តសៀមរាបនោះ បានទទួលជោគជ័យក្នុងការបង្កើនចំនួនអ្នកទេសចរមកកម្ពុជា ប៉ុន្តែវាអាចបណ្តាលឱ្យខាតប្រាក់ចំណូលក្នុងវិស័យទេសចរទៅវិញ ។ ក្រសួងទេសចរបានអោយដឹងថា ភ្ញៀវមកតាមសៀមរាប មានរយៈពេលស្នាក់នៅខ្លីជាងភ្ញៀវមកតាមភ្នំពេញប្រហែលពីរដង ។

តាំងពីឆ្នាំ១៩៩៩ មក ឧស្សាហកម្មទេសចរកម្ពុជា បានរីកលូតលាស់ក្នុងកំរិតគួរអោយចាប់អារម្មណ៍យ៉ាងខ្លាំង ។ ប៉ុន្តែជាអកុសល ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាជាតិសំរាប់កុមារ និងអង្គការទស្សនៈពិភពលោកបានសិក្សាឃើញថា ទេសចរណ៍ផ្លូវភេទកំពុងកើនឡើងលឿនដូចគ្នា ក្នុងនេះមានទាំងអាជីវកម្មខាងផ្លូវភេទលើកុមារផងដែរ ។

វិស័យទូរគមនាគមន៍ ទោះបីមានទំហំតូចនៅឡើយ ប៉ុន្តែមានអាត្រាលូតលាស់យ៉ាងខ្លាំង ពិសេសនៅតាមទីក្រុង ។ តាមពត៌មានពីក្រសួងប្រៃសណីយ៍ និងទូគមនាគម៏ នៅត្រីមាសទី១ ឆ្នាំ២០០១ ប្រទេសកម្ពុជាមានអ្នកប្រើប្រាស់ទូរស័ព្ទដៃចំនួន ១៥១.៨០២នាក់ និងអ្នកប្រើប្រាស់ទូរស័ព្ទខ្សែ ចំនួន ៣១.៤៣៣នាក់ ។ ធៀបនឹងត្រីមាសទីមួយឆ្នាំមុន ចំនួនអ្នកប្រើ ទូរស័ព្ទដៃបានកើន ៥៥% ឯអ្នកប្រើទូរស័ព្ទខ្សែកើន ៨% ។ តាមតួលេខខាងលើប្រទេសកម្ពុជា មានអ្នកប្រើប្រាស់ទូរស័ព្ទខ្សែ ៥ដង តិចជាងអ្នកប្រើប្រាស់ទូរស័ព្ទដៃ គឺសំរាប់ទូទាំងប្រទេស អត្រាអ្នកប្រើប្រាស់ទូរស័ព្ទខ្សែ មានតែ ២៦នាក់ប៉ុណ្ណោះ ក្នុងប្រជាជន ១០.០០០នាក់ ។ មួយចំណែកទៀត ទោះបីជាកម្ពុជា មានក្រុមហ៊ុនទូរស័ព្ទចលត័ជាច្រើនក៏ដោយ ក៏មិនទាន់មានក្រុមហ៊ុនឯកជនណាមួយ ដែលធ្វើការវិនិយោគលើការរាយបណ្តាញទូរស័ព្ទខ្សែសំរាប់ទូទាំងប្រទេសឡើយ ។ ប៉ុន្តែគួរឱ្យត្រេកអរណាស់ដែលក្រសួងប្រៃសណីយ៍ និងទូគមនាគម៏បានទទួលជំនួយពីរដ្ឋាភិបាលជប៉ុន ហើយបានកសាងផែនការ មេ ដើម្បីរាយបណ្តាញភ្ជាប់ទូរស័ព្ទខ្សែ អោយបានទូទាំងប្រទេស នៅត្រឹមឆ្នាំ ២០១០ ។

នៅពេលដែលតំរូវការប្រើប្រាស់សេវាទូរស័ព្ទកំពុងកើនឡើង កំណើនចំនួនអ្នកប្រើប្រាស់អ៊ិនធឺណិត ដូចជានៅខ្សោយនៅឡើយ ។ មកទល់សព្វថ្ងៃចំនួនអ្នកប្រើប្រាស់អ៊ិនធឺណិតនៅមានកំរិតនៅឡើយទេ ដោយសារកង្វះខាតបណ្តាញទូរស័ព្ទខ្សែ និងតំលៃដ៏ខ្ពស់នៃការប្រើប្រាស់សេវាអ៊ិនធឺណិត ។ មកដល់ត្រីមាសទី១ ឆ្នាំ២០០១ នៅក្នុងប្រទេសកម្ពុជាមានអ្នកប្រើប្រាស់អ៊ិនធឺណិតចំនួន ៣.៧៣៣នាក់ ក្នុងនេះ ៥៣% ជាអតិថិជនរបស់ក្រុមហ៊ុនអ៊ិនធឺណិតឯកជន Bigpond និង ៤៧% ជាអតិថិជនរបស់ Camnet នៃក្រសួងប្រៃសណីយ៍ និងទូរគនាគមន៍ ។

# តាមដានសេដ្ឋកិច្ច_សកម្មភាពក្នុងប្រទេស

## អតិផរណា និងអត្រាប្តូរប្រាក់

តាមតួលេខនៃវិជ្ជាស្ថានជាតិស្ថិតិ អត្រាអតិផរណានៅភ្នំពេញគឺ -0,៨% នៅក្នុងត្រីមាសទី១ ឆ្នាំ២00១ ក្នុងនេះថ្លៃម្ហូបអាហារបានធ្លាក់ចុះខ្លាំងជាងគេ បើធៀបនឹងថ្លៃទំនិញផ្សេងទៀត ។ ក្នុងពេលជាមួយគ្នានេះដែរ នៅតាមបណ្តាខេត្តមានអត្រាអតិផរណា ៤,៨% គឺកើនពីអត្រា 0,៦% ប៉ុណ្ណោះកាលពីត្រីមាសទី១ ឆ្នាំ២000 ។ នៅត្រីមាសទី១ ឆ្នាំ២00១ ប្រាក់រៀលបានធ្លាក់ថ្លៃបន្តិច (មិនដល់១% ផង) ធៀបនឹងប្រាក់ដុល្លារអាមេរិក តែវាបានឡើង ថ្លៃធៀបនឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ពីព្រោះប្រាក់បាត និងប្រាក់ដុងបានចុះថ្លៃធៀបនឹងប្រាក់ដុល្លារ ។ ដូច្នេះទំនិញនាំចូលពីវៀតណាម និងថៃ នឹងត្រូវចុះថោកសំរាប់អ្នកប្រើប្រាស់នៅកម្ពុជា ។ ម្យ៉ាងវិញទៀត បើធៀប នឹងត្រីមាសទី៤ ឆ្នាំ២000 ថ្លៃមាសបានបន្តធ្លាក់ចុះ ថ្លៃប្រេងម៉ាស៊ូតនៅ នឹងដដែល ហើយប្រេងសាំងបានធ្លាក់ចុះជិត ៦% ។

## ស្ថានភាពក្រីក្រ ~ ប្រាក់ចំណូលរបស់កម្មករ

កំណើនសេដ្ឋកិច្ចអាចកាត់បន្ថយភាពក្រីក្របានជាក់ស្តែង លុះណាតែមានក្នុងពេលជាមួយគ្នានោះ នូវការប្តេជ្ញាចិត្តធ្វើអភិវឌ្ឍន៏គ្រប់ជ្រុងជ្រោយខាងសង្គមកិច្ច (អប់រំ សុខាភិបាល...) ។ ដោយហេតុមិនសូវសំបូណ៌ធនធានសំរាប់ការអភិវឌ្ឍន៏ខាងសង្គមកិច្ច ការកាត់បន្ថយភាពក្រីក្រនៅតែជាការងារចំបងរបស់ប្រទេសកម្ពុជាសំរាប់ច្រើនឆ្នាំទៅមុខទៀត ។ តាមអង្កេតពលករងាយរងគ្រោះក្នុងក្រុងភ្នំពេញធ្វើឡើងដោយ វិបសអ កាលពីខែឧសភា ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង អ្នករើសអេតចាយ និងកម្មករសំណង់មានជំនាញបានធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ បើធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន (តារាង៥) ។ តាមពត៌មានទទួលបាន ការធ្លាក់ចុះបណ្តាលមកពីការប្រកួតប្រជែងពីសំណាក់កម្មករចំណាកស្រុកបណ្តោះអាសន្នមកពីតំបន់ជនបទ ។ អង្កេតបានបង្ហាញថា ៨0% នៃអ្នកធាក់ស៊ីក្លូ អ្នកលក់បន្លែតូចតាច និងអ្នករត់ម៉ូតូឌុប គឺជាជនចំណាកស្រុកបណ្តោះអាសន្នមកពីខេត្តនានាដែលនៅជាប់ក្រុងភ្នំពេញ ។

ក្នុងចំណោមពលករងាយរងគ្រោះ អ្នកប៉ះពាល់ធ្ងន់ជាងគេ គឺអ្នករើសអេតចាយដែលប្រាក់ចំណូលបានធ្លាក់ចុះ ៤៦% បើធៀបនឹងខែឧសភា ឆ្នាំ២000 ។ មូលហេតុ គឺប្រហែលមកពីមានជនចំណាកស្រុកកាន់តែច្រើនឡើង បានមករកស៊ីរើសអេតចាយនៅពេលមិនអាចរកការងារមានប្រាក់កំរៃច្រើននៅក្នុងទីក្រុង ។ អ្នករើសអេតចាយដែលឆ្លើយសំភាសន៏នៅក្នុងអង្កេតវិបសអ កាលពីខែឧសភា ឆ្នាំ២00១ បានប្រាប់ថា ខ្លួនបានធ្វើសំណាកស្រុកមកភ្នំពេញ ដោយសារផលវិបាកនៃទឹកជំនន់ដ៏ធ្ងន់ធ្ងរក្នុងឆ្នាំ២000 ។ ពួកគាត់បានរាយការណ៏បន្តថា ប្រាក់ចំណូលរបស់គាត់បានធ្លាក់ចុះក្នុងខែឧសភា ដោយសារការប្រកួតប្រជែងដូចលើកខាងលើ និងដោយសារដល់រដូវភ្លៀង គាត់ឈឺថ្កាត់ច្រើន ហើយត្រូវខកខានធ្វើការងារជាញឹកញាប់ ។ ៦៥% នៃអ្នករើសអេតចាយនៅក្នុងអង្កេតបានប្រាប់ថា ជួនកាលចំណូលប្រចាំថ្ងៃរបស់គាត់បានតិចពេករហូតមិនអាចទិញអាហារបាន ហើយត្រូវខ្ចីប្រាក់គេ ដើម្បី យកមក ដោះស្រាយការហូបចុក ។

កម្មករសំណង់មានជំនាញក៏មានការប៉ះពាល់ធ្ងន់ដែរ ទោះបីប្រាក់ចំណូលរបស់ក្រុមនេះមិនទាបដូចអ្នករើសអេតចាយក៏ដោយ ។ គាត់មានយោបល់ថា ការធ្លាក់ចុះប្រាក់ចំណូលវាកើតចេញពីសភាពការណ៏ស្ទៀមស្ទឹក (stagnancy) ក្នុងវិស័យសំណង់ ដែលជាផលវិបាកនៃការធ្លាក់ចុះវិនិយោគផ្ទាល់ពីបរទេស ។ ចំពោះកម្មកររោងចក្រកាត់ដេរវិញ ប្រាក់ចំណូលប្រចាំថ្ងៃបានធ្លាក់ចុះ ៩% (ពី ៨.៥00រៀលក្នុងខែឧសភា ឆ្នាំ២000 ដល់ ៧.៥00រៀលក្នុងខែ ឧសភា ឆ្នាំ២00១) ។ ពួកកម្មករកាត់ដេរបានលើកថា ការធ្លាក់ចុះកើតចេញពីការងារបន្ថែមម៉ោងតិចជាងមុន ហើយរោងចក្រខ្លះបានកាត់ម៉ោងធ្វើការមកត្រឹម ៨ម៉ោងក្នុងមួយថ្ងៃ ។ ទោះបីជាម៉ោងធ្វើការខ្លីជាងមុន និងម៉ោងបន្ថែមតិចជាងមុន បានធ្វើឱ្យថយប្រាក់ចំណូលក៏ដោយ ក៏កម្មករប្រាប់ថា ចំណាយព្យាបាលជំងឺ បានថយចុះដែរ ពីព្រោះមិនធ្វើការយ៉ាប់ដូចមុន ។

ដោយគ្មានទិន្នន័យស្រង់ដោយអង្កេតទ្រង់ទ្រាយធំ ដូច្នេះពិបាកនឹងសន្និដ្ឋានបានថា សមាមាត្រនៃភាពក្រីក្របានកើនឡើងឬថយចុះ ប៉ុន្តែ តួលេខស្តីពីប្រាក់ចំណូលហាក់បានបង្ហាញថា វាបានកើនឡើង ។ ប៉ុន្តែចំពោះចំណាកស្រុកពីខេត្តនានាចូលមកក្រុងភ្នំពេញ គេមានជំនឿថា វាកំពុងកើនឡើង ដោយសារសំពាធនៃកំណើនប្រជាជន ។ បើសិនជាពលករងាយរងគ្រោះក្នុងក្រុងភ្នំពេញមិនអាចរកចំណូលចិញ្ចឹមជីវិតបានគ្រប់គ្រាន់ ឬសន្សំប្រាក់បានខ្លះសំរាប់ទ្រទ្រង់ក្រុមគ្រួសារពួកគេ, បញ្ហាចោទ និងការរំជើបរំជួលក្នុងសង្គមនឹងអាចកើតមានឡើង ។

## ការវិវត្តន៏នៃរូបិយវត្ថុ

ប្រភពពត៌មានពីធនាគារជាតិនៃកម្ពុជាបានឱ្យដឹងថា ការអនុវត្តន៏ច្បាប់ថ្មីស្តីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុបាននាំដល់ការបិទទ្វារ ១១ធនាគារដែលមិនអាចរស់បាន និងដែលមិនអាចបំពេញបានតាមលក្ខខណ្ឌមូលធនចុះបញ្ជីដែលច្បាប់ថ្មីបានតំរូវឡើង ។ ក្នុងឆ្នាំ១៩៩៨ មាន ៣0ធនាគារចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា គឺមានធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជាមួយដែលជាធនាគាររដ្ឋ, ២២ធនាគារដែលជារបស់អ្នកវិនិយោគក្នុងស្រុក, និង ៧ធនាគារជាសាខារបស់ធនាគារបរទេស ។ មកដល់ខែមិនា ២00១ មាននៅសល់តែ ២១ធនាគារទេ គឺធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា, ១៣ធនា គារឯកជន, ៤សាខាធនាគារបរទេស, និង ៣ធនាគារឯកទេស ។ ធនាគារពាណិជ្ជកម្មក្រៅប្រទេសសព្វថ្ងៃកំពុងស្ថិតក្នុងដំណាក់កាលធ្វើឯកជនភាវូបនីយកម្ម ដែលត្រូវចប់ស្រេចបាច់នៅចុងឆ្នាំ២00១ ។ ធនាគារនេះរំពឹងថា នឹងបើកសាខានៅតាមបណ្តាខេត្តក្នុងអំឡុង៣ឆ្នាំខាងមុខ ។

ទ្រព្យសកម្មបរទេសសុទ្ធ របស់ធនាគារនៅក្នុងត្រីមាសទី១ ឆ្នាំ២00១ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២000 បានកើនជិតដល់ ១២%, ប៉ុន្តែ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ បានថយចុះប្រហែល ២៣% ។ ក្នុងត្រីមាសទី១ ឆ្នាំ២00១ ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល (net claims on the government) បាន ឡើង ដល់កំរិតខ្ពស់បំផុតក្នុង ៨ឆ្នាំកន្លងមក ។ ផ្អែកតាមតួលេខទាំង នេះ គេអាចសន្និដ្ឋានថា មានការហូរចេញពីប្រទេសកម្ពុជា នូវមូលធន ។

ក្នុងត្រីមាសទី១ ឆ្នាំ២00១ ការផ្គត់ផ្គង់រូបិយវត្ថុទៅទីផ្សារមានសរុប ៥១១ពាន់លានរៀល ។ តួលេខនេះ បង្ហាញកំណើនដ៏តូចមួយ (0,៤%) ធៀបនឹងត្រីមាសទី១ ឆ្នាំ២000 ។ ប្រាក់បញ្ញើជារូបិយប័ណ្ណនៅក្នុងធនាគារពាណិជ្ជមានសរុប ១.៣0៣ពាន់លានរៀល គឺកើន ១0% ធៀបនឹងត្រីមាសទី១ ឆ្នាំ២000 ។ វិធានការក្រោយៗបំផុតបង្ហាញថា ធនាគារជាតិនៃ

# តាមដានសេដ្ឋកិច្ច-សកម្មភាពក្នុងប្រទេស

កម្ពុជាបានឈានយ៉ាងលឿនទៅដោះស្រាយចំណុចខ្សោយដែលបានអូសបន្លាយជាងមួយឆ្នាំមកហើយនៅក្នុងវិស័យធនាគារ ហើយការប្ដេជ្ញាធ្វើកំណែទំរង់សំដៅបំរើសេដ្ឋកិច្ចទីផ្សារ នឹងនាំឱ្យមានស្ថិរភាពសេដ្ឋកិច្ច និងការប្រកួតប្រជែង កាន់តែប្រសើរឡើង ។

## ហិរញ្ញវត្ថុសាធារណៈ

តាមប្រភពពត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណូលសរុបរបស់រដ្ឋាភិបាលក្នុងត្រីមាសទី១ ឆ្នាំ២០០១ ប្រមូលបានទាបជាងគំរោងថវិកា (៤០៧ពាន់លានរៀល) ដល់ទៅ ១១% ។ ប៉ុន្ដែចំណូលនេះបានកើន ៩% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០០ ។ លទ្ធផលល្អនៃចំណូលមិនមែនពន្ធ និង ចំណូលពន្ធ (ពន្ធលើប្រាក់បៀវត្សរ៍, និងអាករលើតំលៃបន្ថែម VAT) គឺជាកត្តា ដែលនាំឱ្យមានកំណើនចំណូលខាងលើ ។ លើសពីនេះទៀត រដ្ឋាភិបាលមានផែនការពង្រីក VAT ទៅតាមខេត្តក្នុងឆ្នាំ២០០១ នេះ ដើម្បីបង្កើនចំណូលថែមទៀត ។ ការពង្រីកការប្រមូល VAT ជាជាងការបង្កើនពន្ធគយត្រូវបានដាក់អនុវត្ត ពីព្រោះពន្ធគយនឹងត្រូវធ្វើសុខុមនីយកម្ម (harmonisation) ក្នុងពេលអនាគតទៅតាមអត្រាពន្ធដែលអនុវត្តនៅក្នុងអាស៊ាន ។

ខាងផ្នែកចំណាយវិញ ក្នុងត្រីមាសទី១ ឆ្នាំ២០០១ ចំណាយសរុបត្រូវបានរឹតបន្តឹង (ថយចុះជិតដល់ ៦% បើធៀបនឹងឆ្នាំមុន) ។ ចំណាយចរន្តក៏ធ្លាក់ចុះដែរ គឺថយចុះ ៣៨% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០០ ។ ចំណាយខាង អប់រំបានកើន ៣%ក្នុង ត្រីមាសទី១ នេះ ឯចំណាយខាងសុខាភិបាលបាន ថយចុះ ៤៧% ។ ការធ្លាក់ចុះយ៉ាងគំហុកនេះ បានធ្វើឱ្យឱនភាពថវិកាថយចុះ ដែរ ។ ប៉ុន្ដែតាមគំរោងថវិកាដែលត្រូវបានអនុមតិសំរាប់ឆ្នាំ២០០១ ចំណាយខាងអប់រំ និងសុខាភិបាល ត្រូវកើនឡើង ១៧% និង ១៨% ។ គំរោងថវិកាក៏បានកំណត់ចំណាយខ្ពស់ជាងផងដែរសំរាប់ វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងចំនាយទាបជាងមុនសំរាប់ខាងយោធា ។ ថវិកាសំរាប់ខាងយោធានិងសន្ដិសុខជាតិត្រូវបានកំណត់ ៥%ទាបជាងថវិកាសំរាប់ឆ្នាំ២០០០ ។ ប៉ុន្ដែនៅក្នុងពេលកន្លងមក ចំណាយជាក់ស្ដែងក្នុងវិស័យនេះ មានកំរិតខ្ពស់ជាងការគ្រោងទុក ។ ចំណាយរដ្ឋាភិបាល តាមធម្មតាតែងតែខ្ពស់ជាងចំណូលថវិកា ។ ដើម្បីបំពេញឱនភាពនេះ រដ្ឋាភិបាល ត្រូវពឹងផ្អែកទៅលើជំនួយបរទេស ។

## វិនិយោគទុន និងទីផ្សារពលកម្ម

